**មជ្ឈមណ្ឌលឯកសារកម្ពុជា**

**សម្ភាសជាមួយ សួស ធី, អាយុ៥៣ឆ្នាំ ម្ចាស់ប្រវត្តិរូប K09089**

**មុខងារសម័យខ្មែរក្រហមៈ អ្នកកាន់បញ្ជីនៅស-២១**

**នៅភូមិព្រែកកែវ ឃុំកោះខែល ស្រុកស្អាង ខេត្តកណ្ដាល**

**ថ្ងៃទី២០ ខែតុលា ឆ្នាំ២០០៤**

សម្ភាសដោយ ដាន់ សុជា, ឡុង ដានី, អឿ រតនា

សំគាល់ៈ សុជា=ដាន់ សុជា, ធី=សួស ធី

**សរុបៈ ៣០ទំព័រ**

**សុជាៈ** លោកពូខ្ញុំម៉ោសួរពូថ្ងៃនេះ ខ្ញុំចង់សួររឿងបន្ថែមចំនុចខ្លះ ដូចថាកាលខ្ញុំសួរពូកាលលើកមុនហ្នឹងវានៅខ្វះ ហើយខ្ញុំចង់សួរពីរឿងដែលបង្ហាញថា ឌុច, ចាន់, ហ៊ួ, ប៉ុន, ទុយ អីហ្នឹងឲ្យបានច្រើនជាងមុនព្រោះកាលមុនខ្ញុំសួរអត់សូវបានសង្កត់ធ្ងន់ទៅលើរឿងហ្នឹង ហើយនិងរឿងមួយទៀតរឿងការចំរាញ់ដូចពូបានលើកនិយាយថា អ្នកយាមអ្នកធ្វើការនៅក្នុងស-២១ ហ្នឹង មួយចំនួនត្រូវបានគេចំរាញ់ ដកចេញ ឬក៏ចាប់ ហើយពូផ្ទាល់ហ្នឹងក៏ជាមុខសញ្ញាមួយនៃការដក ចំរាញ់ចេញរបស់គេដែរ មិនអញ្ចឹងហ៎ពូ ព្រោះថាគេឲ្យក្មេងម្នាក់ម៉ោឲ្យធ្វើការពីអមលាំងម៉ោធ្វើការជាមួយពូហ្នឹង ហើយខ្ញុំចង់សួរថា ឌុចនៅទួលស្លែងហ្នឹង ឋានៈគាត់ធំជាងគេហ្នងហ៎ គេហៅប្រធានហ្នងហ៎?

**ធីៈ** គាត់ប្រធានមន្ទីរស-២១ហ្នឹងហ្នង ប៉ុន្តែកាលពីមុនគាណាតទេបើនិយាយពីប្រវត្តិមន្ទីរស-២១ កាលមុនវាសេនាធិការ កាលហ្នឹងគាហ្នឹងគាត់ជាប្រធានកងពល ដល់ប្រធានកងពលម៉ោក្រោយម៉ោគាត់ថាមានរៀបចំធ្វើជាមន្ទីរ មុនដំបូងមិនដឹងមន្ទីរអីទេខ្ញុំមិនបានដឹងទេ ប៉ុន្តែដឹងថារបស់សេនាធិការ ហើយពួកអ្នកដែលចាប់នៅស-២១ហ្នឹង ក៏អត់មានដាក់ស-២១ដែរ ដាក់តែសេនាធិការទេ បើយើងរកមន្ទីរស-២១យើងរកអត់ឃើញទេ។

**សុជាៈ** មុនដំបូងហ្នឹងហ៎?

**ធីៈ** អត់ទេឥឡូវហ្នឹងក៏ដោយបើយើងដាក់សេនាធិការទាំងអស់ ព្រោះអាណឹងក្រោមការក្តោបក្តាប់របស់សេនាធិការ មន្ទីរស-២១ហ្នឹង។

**សុជាៈ** ចុះពេលឌុចហ្នឹងម៉ោគ្រប់គ្រងទៅទួលស្លែងហ្នឹងនៅឆ្នាំណា?

**ធីៈ** ខ្ញុំមិនច្បាស់ដែរ ភ្លេចហើយបែបខ្ទង់៧៦អីហ្នឹង អត់ច្បាស់ទេទាល់តែសួរឌុចទៅបានដឹង អាណឹងយើងនិយាយស្មានៗ អត់ច្បាស់ណា៎។

**សុជា៖** ពេលដែលខុចម៉ោគ្រប់គ្រងហ្នឹង ចាន់, ហ៊ូ អីមានហើយឬនៅ ឬក៏នៅពួកចាន់, ប៊ុន, ហ៊ូអីហ្នឹងម៉ោក្រោយខុចទេ?

**ធី៖** ខ្ញុំមិនបានដឹងច្បាស់គេម៉ោពីណាទេ ព្រោះខ្ញុំនៅខាងការពារណោះ ដូច្នេះគេខាងផ្នែកខុចហ្នឹងគេម៉ោម៉ោហ្នឹងកាលហ្នឹងតាណាតនៅហ្នឹងដែរទេ ដល់បន្តិចបានគេដកតាណាតហ្នឹងទៅ ហើយពួកគេយកកម្លាំងគេម៉ោធ្វើការហ្នឹងខ្ញុំអត់បានដឹងច្បាស់ទេ ព្រោះអីខាងគេណោះ ។

**សុជា៖** តែគ្នាពូដែលធ្វើការជាមួយតាណាតមុនដំបូងហ្នឹងនៅទាំងអស់គ្នា ឬក៏មានការយកទៅណាទៅណែខ្លះ?

**ធី៖** បើនិយាយបើយកយកចង់អស់ ចង់ពាក់កណ្ដាលនោះ បើមើលក្នុងបញ្ជីរបស់សេនាធិការអស់ច្រើនណាស់ អ្នកដែលម៉ោពីកងពល១២, អាណឹងកាលមុននៅកងពល១២ទាំងអស់តើ ប៉ុន្តែកងពល១២វាចំណុះឲ្យសេនាធិការណ៎ តែចាប់អស់ច្រើនណាស់ ។

**សុជា៖** ចាន់នេះត្រូវជាម៉េច ដែលថាមុខដំណែងគាត់ជាម៉េចចាន់ហ្នឹង?

**ធី៖** ចាន់ហ្នឹងខ្ញុំដឹងវាមិនច្បាស់ទេ អាណឹងវានៅក្នុងផ្នែកសួរចម្លើយ ។

**សុជា៖** ចុះអ្នកដែលអតីតម៉ោពីកងពល១២ដែរ ឬក៏?

**ធី៖** អត់ទេ ចាន់ មែនម៉ោពីកងពល១២ទេ ។

**សុជា៖** ចុះម៉ោពីណាដែរ?

**ធី៖** មិនបានដឹងច្បាស់ដែរ ប៉ុន្តែវាម៉ោជាមួយខុចហ្នឹង ។

**សុជា៖** ចុះហ៊ូ?

**ធី៖** ហ៊ូហ្នឹងបានម៉ោពីកងពល១២ ។

**សុជា៖** ហ៊ូហ្នឹងក្រែងមានពីរហេ៎ពូ?

**ធី៖** ហ៊ូហ្នឹងមួយនៅនេះ អាណឹងផ្សេង ។

**សុជា៖** ហ៊ុយទេហេ៎?

**ធី៖** ហ៊ុយក៏ពីរ ហ៊ូក៏ពីរដែរ ។

**សុជា៖** ហ៊ូមួយទៀតនៅណា?

**ធី៖** មួយទៀតនៅកងពល១២ហ្នង អត់មានម៉ោចូលធ្វើការហ្នឹងទេណ៎ បើហ៊ុយក៏មានពីរដែរ ។

**សុជា៖** ចុះហ៊ូផ្ទះយើងត្រើយស្ពានេះហេ៎?

**ធី៖** បាទ!

**សុជា៖** តែគាត់ហ្នឹងខ្វាក់ភ្នែកមួយខាងអត់ទេ?

**ធី៖** វាមែនខ្វាក់ទេ វាសំលៀង វាត្រូវគ្រាប់ ។

**សុជាៈ** ហ៊ូហ្វ៊ីនកាលនៅកងពល១២ នៅផ្នែកអីដែរ?

**ធីៈ** ខាងកងពិសេស ។

**សុជាៈ** ប្រធានកងពិសេស?

**ធីៈ** បាទ!

**សុជាៈ** អញ្ចឹងបានន័យថាហ៊ូ ហ្វ៊ីនទៅកាន់ការនៅទួលស្លែងមុនឌុច អីក៏ក្រោយឌុច?

**ធីៈ** បែបមុនហើយ ព្រោះកាលមុនតាណាតណ៎ា តាណាតគាត់ប្រធានកងពល ។

**សុជាៈ** តែដល់ពេលនេះគេបញ្ចូល ឌុចទៅ ហ៊ូហ្វ៊ីនក៏នៅតែជាអនុរបស់ឌុច ដដែល?

**ធីៈ** តែកាលមុនដែលហ៊ូហ្វ៊ីន អត់បានជាអនុរបស់តាណាតទេណ៎ា គាត់ដូចថា គ្រាន់តែជាបញ្ញាការ វរៈដដែលទេ គ្រាន់តែថាព្រោះគេឋានៈគេកងពល ឋានៈវរសេនាតូចខុសគ្នា ដូច្នេះកាលហ្វ៊ីន តាណាតកាន់ម្នាក់ឯងទេ ។

**សុជាៈ** ចុះបើនៅខាងទួលស្លែងនោះ ហ៊ូហ្វ៊ីនអនុប្រធាន?

**ធីៈ** បាទ! អនុប្រធាន ។

**សុជាៈ** តែអនុប្រធានហ្វ៊ីនប៉ុន្មាននាក់?

**ធីៈ** អត់ទេមានតែមួយទេ ហ៊ូ ហ្វ៊ីន ។

**សុជាៈ** ចុះចាន់?

**ធីៈ** អាណឹងផ្នែកសួរចម្លើយ ។

**សុជាៈ** ប្រធានក្រុមសួរចម្លើយ អីក៏យ៉ាងម៉េច?

**ធីៈ** គេមិនដឹងជាចាត់តាំងយ៉ាងម៉េច ព្រោះអាណឹងផ្ទៃក្នុងគេ យើងតូចតាចវាមិនអាចដឹងទេ អត់ដឹងច្បាស់ទេ ។

**សុជាៈ** តែគ្រាន់តែថា ឌុច ហ្វ៊ីនប្រធាន, ហ៊ូហ្វ៊ីនអនុប្រធាន?

**ធីៈ** បាទ! ហ៊ុយហ្វ៊ីនសមាជិក ។

**សុជាៈ** ហ៊ុយ ណា? ហ៊ឹម ហ៊ុយហ្វ៊ីនហ៎ា?

**ធីៈ** មែនទេ, ហ៊ុយ ស្រែ អាណឹងគេគណៈកម្មាធិការស-២១ ។

**សុជាៈ** កាលហ្វ៊ីនគេចែកថា ហ៊ុយ ស្រែហ្វ៊ីនគេខាងសេដ្ឋកិច្ច?

**ធីៈ** បាទ! ខាងសេដ្ឋកិច្ច តែខាងសមាជិកខាងសេដ្ឋកិច្ចហើយ ។

**សុជាៈ** ចុះប៉ុន?

**ធីៈ** អូហ៍! អាណឹងខ្ញុំមិនអាចដឹងផ្ទៃក្នុងគេទេ ព្រោះជួនកាលផ្ទៃក្នុងគេ គេអាចធំជាងណាតក៏មិនដឹង ព្រោះយើងមិនអាចស្មានទេ ព្រោះក្នុងការដឹកនាំយើងមិនបានដឹងទេ ។

**សុជាៈ** តែប៉ុនហ្នឹងគាត់ធ្វើការខាងអីគេ?

**ធីៈ** សួរចម្លើយដូចគ្នា ។

**សុជាៈ** ទុយ ហ្នឹងក៏សួរចម្លើយដែរ?

**ធីៈ** បាទ!

**សុជាៈ** អញ្ចឹងវាមានឌុច មានចាន់ មាន ហ៊ួ, មានប៉ុន មានទុយ, ឌុចជាអ្នកក្តាប់រួម?

**ធីៈ** រួមទាំងអស់ ។

**សុជាៈ** ចុះហ៊ួ គាត់អនុប្រធានមែន តែគាត់កាន់ខាងផ្នែក?

**ធីៈ** កាន់ខាងការពារ, កងការពារ ។

**សុជាៈ** ចុះចាន់ ប៉ុន ហើយនិងទុយហ្នឹងផ្នែកខាងសួរចម្លើយ?

**ធីៈ** សួរចម្លើយ ។

**សុជាៈ** ចុះបីនាក់ហ្នឹងណាគេធំជាងគេ?

**ធីៈ** មិនដឹងទេ រឿងចាត់តាំងគេអត់ដឹងច្បាស់ រឿងតួនាទី ។

**សុជាៈ** ចុះពូខ្ញុំធ្លាប់សួរគេមួយឈ្មោះ ពូស្គាល់ទេឈ្មោះឈិន, ឆែម ឈិន នៅកណ្តាលស៊ីធណក់?

**ធីៈ** មិនដឹងមួយណាទេ ។

**សុជាៈ** រឿងមាឌល្អិតគាត់ហ្នឹង ដូចនៅខាងកងការពារដែរ ។

**ធីៈ** ខ្ញុំចាំអត់អស់ព្រោះកងការពារវាច្រើន ១៧-១៨ក្រុម កាលមុន៣០០នាក់ ប៉ុន្តែដល់ក្រោយម៉ោចាប់អី ដកអីអស់ហើយនៅសល់ប្រហែលជាង១០០ទេ ទាល់តែគេអ្នកក្តាប់កងការពារបានដឹង ។

**សុជាៈ** សមាជិកគេមានតួនាទីធ្វើអីខ្លះ?

**ធីៈ** អាណឹងបើនិយាយរួមខាងសេដ្ឋកិច្ចហ្នង ដោះស្រាយ ។

**សុជាៈ** ចុះសមាជិកក្រៅពីហ៊ុយ ហ្នឹងមានណាគេទៀត?

**ធីៈ** អត់ទេមានតែបីនាក់ហ្នឹងទេ ចាត់តាំងវាមានតែបីទេ អត់ដែលចាត់តាំង ដូចក្នុងទ័ពក៏មានតែបីដែរ ។

**សុជាៈ** ចុះដូចឌុចហ្នឹង គាត់អ្នកគ្រប់គ្រងនៅហ្នឹងអញ្ចឹង ពូខស្សាហ៍ជួបគាត់ទេ?

**ធីៈ** អត់ទេ ខ្ញុំនៅដាច់ដោយឡែកពីគ្នា ព្រោះគេណោះគេលាក់ការណ៍ គ្រាន់តែកងការពារយើងអត់មានសិទ្ធិទៅសួរគេបានទេ មិនបាច់ដល់អ្នកសួរចម្លើយទេ អត់មានសិទ្ធិទេ ទៅស៊ីបាយក៏ក្រុមដោយក្រុមដែរ អត់មានទៅហូបបាយក្រុមនេះទៅហូបជាមួយក្រុមនោះបានទេ ។

**សុជាៈ** ហើយពេលញ៉ាំបាយអីចឹង ពូមានបានឃើញគាត់អីដែរ, ឌុចអី?

**ធី:** ពេលហូបបាយធ្លាប់ឃើញដែរ ព្រោះហូបរួមក្នុងរោងតែមួយ ។

**សុជា:** តើនៅក្នុងស-២១ហ្នឹង ការរៀបចំគ្រប់គ្រងរបស់គេ ពូអាចដឹងខ្លះទេ ដូចថាគេមានកងការពារ កងសួរចម្លើយ ហើយនិងមានកងអីផ្សេងៗទៀតពូដឹងទេ?

**ធី:** អត់ទេមានតែកងការពារហើយនិងកងសួរចម្លើយ ហើយនិងផ្នែកសេដ្ឋកិច្ចស្រែ ។

**សុជា:** ខ្ញុំសួរគេខ្លះគេថាមានខាងកងចាប់ចង, អ្នកចាប់ចង ។

**ធី:** អាណឹងការពារហ្នឹង ។

**សុជា:** ការពារហ្នឹង?

**ធី:** បាទ!

**សុជា:** ហើយចុះនិរសានោះ?

**ធី:** និរសារក៏នៅក្នុងកងការពារ ពាក្យវាតែមួយ ។

**សុជា:** ចុះពូនៅខាងក្នុងក្រុមកងការពារ?

**ធី:** បាទ! អាណឹងពីមុនកងការពារហ្នឹងវានៅកងពល១២ ហើយយកតាមកងវរសេនាតូចៗម៉ោ ដែលគេយកម៉ោ គេដកម៉ោ ។

**សុជា:** ហើយពូនៅក្នុងកងការពារហ្នឹងពូកាន់ខាងបញ្ជី?

**ធី:** បាទ!

**សុជា:** ហើយបញ្ជីហ្នឹងវានៅក្នុងការគ្រប់គ្រងរបស់កងការពារដែរ?

**ធី:** បាទ!

**សុជា:** អញ្ចឹងអ្នកគ្រប់គ្រងរបស់ពូគឺ?

**ធី:** ហ៊ូ ។

**សុជា:** ហ៊ូម៉ោបានយើងឡើងម៉ោ ឌុចអញ្ចេះ?

**ធី:** បាទ! ប៉ុន្តែកាលមុនមន្ទីរធំបំផុតនៅកន្លែងឌុច, ឌុចគេមានមន្ទីរគេមួយ ។

**សុជា:** ឌុចហ្នឹងនៅមុំណា?

**ធី:** មន្ទីរគេនៅជិតកន្លែងគេហ្នឹង ។

**សុជា:** អាណឹងមន្ទីរអីគេ?

**ធី:** មន្ទីរគេវាមាន យើងរាយការណ៍ទៅកន្លែងមន្ទីរគេ ។

**សុជា:** ឧបមាថាពូខាងអ្នកកាន់បញ្ជីអញ្ចឹងដល់ពេលរាយការណ៍ ពូរាយការណ៍ម៉ោហ៊ូនេះ ឬក៏រាយការណ៍ផ្ទាល់ម៉ោ?

**ធី:** អត់ទេ ទាល់តែម៉ោហ៊ូ, ហ៊ូស៊ីញ៉ៅហើយបានយើងយកទៅឲ្យមន្ទីរឌុច ។

**សុជា:** យើងផ្ទាល់ហ្នឹងគឺអ្នកចាំតែបានស៊ីញ៉ាំពីហ៊ូនេះម៉ាយើង?

**ធី:** យើងអត់មានស៊ីញ៉ាំ យើងអត់ហ៊ានចេញទៅអញ្ចឹងដែរ ការងារអីក៏ដោយក៏ពីហ៊ូគេសម្រេច ។

**សុជា:** ខាងកងការពារ ឧបមាថាកងការពារ និងកងចាប់ចង ឧបមាថាត្រូវទៅចាប់នរណាម្នាក់ពីខាងកងពលណាមួយម៉ោអញ្ចឹង តើហ៊ូនេះបានទទួលបញ្ជាពីខាងណា តើកងចាប់ចងត្រូវទទួលបញ្ជាពីខាងណាម៉ោដើម្បីមានសិទ្ធិទៅចាប់អ្នកក្រៅបញ្ចូល?

**ធី:** អារឿងនេះ រឿងការងារនេះវាខុសតួនាទីខ្ញុំ តែខ្ញុំដឹងមិនច្បាស់ បើខ្ញុំនិយាយទៅក៏វាអត់បានប្រយោជន៍ព្រោះអាណឹងមិនដឹងជាហ៊ូ ប៉ុន្តែបើនិយាយពីការងារអីត្រូវទទួលពីឌុចម៉ោទាំងអស់ ។

**សុជា:** អញ្ចឹងចំណារពីឌុចម៉ោទាំងអស់?

**ធី:** បើមិនចំណារពីឌុចម៉ោទេ អត់មាននិយាយនរណាទាក់ទងបានទេ ។

**សុជា:** ចុះប៉ុន ឬក៏ទុយ, ចាន់អីហឹងមានសិទ្ធិម៉ោបញ្ជាពូអ្នកកាន់បញ្ជី ឬក៏កងនិរសា កងចាប់ចងអីទេ?

**ធី:** អត់ទេ ។

**សុជា:** អញ្ចឹងពូទទួលបញ្ជាពីហ៊ូនេះមួយ និងឌុចនេះទេ?

**ធី:** អត់ទេខ្ញុំឌុចមិនដែលបានទទួលទេ ព្រោះយើងធ្វើអីវាត្រូវក្រោមការ ធ្វើអីក៏ដោយឌុចបញ្ជាម៉ោហ៊ូទាំងអស់ ហ៊ូបានចាត់ចែងរឿងការងារ ព្រោះអានេះវាការងារផ្សេងគ្នា ។

**សុជា:** ពូកត់បញ្ជីអញ្ចឹង អ្នកកាន់នៅហ្នឹងប៉ុន្មាននាក់?

**ធី:** បើរឿងបញ្ជីអ្នកទោសតែខ្ញុំ ហើយនឹងក្មេងម្នាក់ហ្នឹង ។

**សុជា:** ក្មេងហ្នឹងទើបតែយកចូលក្រោយទេ?

**ធី:** ទើបតែយកចូលក្រោយទេ ចុងក្រោយហើយ ។

**សុជា:** ឈ្មោះអីពូក្មេងហ្នឹង?

**ធី:** ឡាន់ ។

**សុជា:** ម៉ោពីខាងណា?

**ធី:** ម៉ោពួកខាងឌុចគេយកម៉ោ សុទ្ធតែកុមារតូចៗ យកម៉ោចង់ជំនួសចង់អស់ហើយ ជំនួសខាងកងការពារ ។

**សុជា:** តូចៗហ្នឹងអាយុប៉ុន្មានពូ?

**ធី:** ជាងដប់ឆ្នាំ ។

**សុជា:** អញ្ចឹងពូខ្ញុំចង់សួរតទៀត ពូអាចដឹងទេពីសិទ្ធិរបស់ស-២១នេះ ដែលថាកាលពីមុនគេហៅថាគុក របស់សេនាធិការអីអញ្ចឹង ហើយក្រោយម៉ោមានការចាប់អ្នកទោសចូលទៅក្នុងហ្នឹងច្រើន

ណាស់ ហើយការចាប់ហ្នឹងបើពួផ្ទាល់មានអ្នកនៅក្នុងហ្នឹងមួយចំនួនក៏ត្រូវគេចាប់ដាក់ក្នុងហ្នឹងតែមិនអញ្ចឹងហេ៎?

**ធី:** បាទ!

**សុជា:** ហើយទៀតអាការចាប់ពីក្រៅទៅទៀត ពួកកងការពារ ឬក៏កងចាប់ចងហ្នឹងទៅចាប់ម៉ោខ្លួនឯងអីក៏ ឧទាហរណ៍អញ្ចេះឧបមាថា នៅក្នុងមន្ទីរកងពល៣១០ ឬ៧០៣ នៅក្រោមអញ្ចឹង ៧០៣ នេះគេមានខាងកងសន្តិសុខរបស់គេដែរ សម្រាប់ចាប់អ្នកទោសម៉ោដាក់កន្លែងហ្នឹងហើយបានយើងពីស-២១នេះទៅយកពីកន្លែងមន្ទីរសន្តិសុខរបស់៧០៣ហ្នឹងតែម្តង ឬក៏កងការពារនេះទៅចាប់គ្រាន់តែទៅសុំការអនុញ្ញាតិពី៧០៣?

**ធី:** ទាល់តែគេណោះគេទៅចាប់ឲ្យ យើងគ្រាន់តែទៅទទួលគេទេ បើតាមខ្ញុំដឹងណា ប៉ុន្តែមិនដឹងពិតប្រាកដទេ ប៉ុន្តែបើតាមខ្ញុំខ្ញុំដឹងវាមិនដែលណាគេយម៉ោឲ្យទាំងអស់ទេ ។

**សុជា:** យើងគ្រាន់តែមានឡានចាំទទួលពីកងពលគេ?

**ធី:** ហ្នឹងហើយយើងចាំដឹកយកម៉ោកន្លែង ប៉ុន្តែអាណឹងខ្ញុំវាមិនច្បាស់ទេណា៎ តែខ្ញុំឃើញដាក់ស្ទែងវាច្រើនអញ្ចឹង ។

**សុជា:** ហើយឡានដែលគេបម្រើការទៅចាប់អ្នកទោសអ្នកអីហ្នឹងប៉ុន្មានឡាន?

**ធី:** អាណឹងវាមានសំខាន់អីគ្រាន់ទៅចាប់ បើនិយាយរឿងទៅចាប់វាតិចណាស់ តែគេយកម៉ោឲ្យដល់ៗកន្លែងហ្នង ។

**សុជា:** មានឡានពីក្រៅម៉ោចូលទួលស្លែងហ្នឹងហ្នង?

**ធី:** ហ្នឹងហើយ យកម៉ោចូលកន្លែងគេនេះហ្នឹងហ្នង កន្លែងស-២១ហ្នឹងហ្នង ។

**សុជា:** ឡានហ្នឹងពូមានចំណាំឡានម៉ោពីខាងណាទេ?

**ធី:** ឡានវាច្រើនដែរ ខាងណាគេម៉ោគេយកឡានរបស់គេម៉ោ ។

**សុជា:** អញ្ចឹងពួកខាងកងការពាររបស់ស-២១មិនសូវចេញទៅចាប់ខ្លួនឯងទេ?

**ធី:** មិនសូវទេច្រើនតែគេបញ្ជូនឲ្យ ។

**សុជា:** មិនសូវមានន័យថាមានដែរ?

**ធី:** មានដែរ ប៉ុន្តែវាមានតិចណាស់ ។

**សុជា:** គេបញ្ជូនម៉ោគេមានបញ្ជូនឈ្មោះអីប្រាប់ឲ្យខាងពូដឹងមុនអីទេ?

**ធី:** អាណឹងវាទៅខាង ទាល់តែគេប្រធានណោះ ទាល់តែឌុចណោះបានដឹង ការងារហ្នឹងយើងមិនដឹងទេ វាសុទ្ធតែការងាររលាក់ការណ៍របស់គេទាំងអស់ ។

**សុជា:** ចុះដល់ពេលគេបញ្ជូនអ្នកទោសម៉ោ តួនាទីរបស់ពូជាអ្នកកាន់បញ្ជីធ្វើយ៉ាងម៉េចដែរ?

ធី៖ ម៉ោគ្រាន់តែកត់ឈ្មោះ ប្រវត្តិរូបហ្នឹងហើយ កត់លេខបន្ទប់លេខអីហើយ ការងារខ្ញុំតែប៉ុណ្ណឹង ។

សុជា៖ ចុះបើគេត្រូវយកអ្នកទោសចេញវិញ?

ធី៖ ចេញក៏គេឲ្យឈ្មោះម៉ោ ឲ្យនេះម៉ោ ខ្ញុំគ្រាន់តែយកចេញទៅតាមឈ្មោះហ្នឹង ។

សុជា៖ តែអ្នកម៉ោទទួលម៉ោអី ក្រុមអី?

ធី៖ ក្រុមការពារ អាណឹងកងការពារទាំងអស់គេជាអ្នកសម្រេច ។

សុជា៖ ចុះអ្នកសួរ កងសួរចម្លើយ?

ធី៖ អត់មាន ការងារផ្សេង ។

សុជា៖ ចុះដល់ពេលយកអ្នកទោសចូលហើយ គេត្រូវយកអ្នកទោសទៅសួរចម្លើយ ពួអ្នកកាន់បញ្ជីហ្នឹង ត្រូវម៉ោផ្ទៀងផ្ទាត់ដែរ អីក៏?

ធី៖ អត់ទេ បើអ្នកទោសថ្មីគេម៉ោផ្ទៀងផ្ទាត់តែមុនដំបូងទេ តែគេស្គាល់លេខបន្ទប់ហើយដល់ក្រោយ ម៉ោគេម៉ោធ្វើខ្លួនគេ គេមិនចាំបាច់យកម៉ោទៀតទេ មុនដំបូងគេអត់ដឹង អ្នកទោសថ្មីគេម៉ោ ផ្ទៀងផ្ទាត់លេខបន្ទប់តែមួយព្រឹក តែមួយភ្លែតហ្នឹង ទាល់តែល្ងាចគេម៉ោដំណើរខ្លួនគេ ។

សុជា៖ គេម៉ោយកអ្នកទោសទៅសួរចម្លើយប៉ុន្មានដងៗអីគេក៏អត់ម៉ោប្រាប់?

ធី៖ គេលែងប្រាប់យើងហើយ ។

សុជា៖ ពីណាគេប្រធានអ្នកសួរចម្លើយហ្នឹង?

ធី៖ មានណាគេ មានតែឌុចហ្នឹង ។

សុជា៖ ឌុចផ្ទាល់ហ្មង ឌុចកាន់ប្រធានសួរចម្លើយផ្ទាល់ មែនប៉ុន ឬក៏ទុយអីអ្នកប្រធានទេហ៎?

ធី៖ បើតាមមើលមានតែឌុចទេ ប៉ុនខ្ញុំតាមមើល ព្រោះសេចក្តីសម្រេចអីរបស់ឌុចទាំងអស់ គ្មានចេះ អត្តនោម័តធ្វើការទេ ។

សុជា៖ តែក្រែងលោថា ការសួរចម្លើយសួរអី ឧបមាថាអ្នកទោសមានកម្រិតផ្សេងៗគ្នា អញ្ចឹងឧបមា ថា ទុយ ឬក៏ចាន់អី ថានៈធម្មតាអីចឹង ជាសមាជិកនៃក្រុមសួរចម្លើយអញ្ចឹង អញ្ចឹងអ្នកទោស ធម្មតាអីចឹង ទុយ, ចាន់នេះអាចសួរបាន តែឧបមាថាវាត្រូវមានការគ្រប់គ្រងលើហ្នឹងទៀត លើទុយ លើចាន់ លើប៉ុនហ្នឹង ក្រែងលោកថា មានឌុចហ្នឹងជាប្រធានហ្មង ឬក៏មានប៉ុននេះជា ប្រធាននៅក្នុងក្រុមសួរចម្លើយ?

ធី៖ អត់ទេ ឌុចហ្នឹង ។ តាមខ្ញុំដឹងការងារអីក៏ដោយទាល់តែពីលើហ្នឹងម៉ោ ប្រាប់តម្រង់បានពីក្រោម ហ៊ាន ។

សុជា៖ ឧបមាថា ឥឡូវចាត់នរណាឲ្យទៅសួរចម្លើយ ឧបមាថា ចាន់, ទុយ អីហ្នឹងទៅសួរទាំងបីនាក់ ឬ ក៏ទៅសួរម្នាក់ៗ?

**ធី:** អាណឹងវាសុទ្ធតែម្នាក់ៗ រៀងៗខ្លួនទាំងអស់ហ្នឹង តាមមើល ។

**សុជា:** អញ្ចឹងអ្នកណាចាត់ឲ្យពួកហ្នឹងអ្នកធ្វើការ អ្នកណាជាអ្នកចាត់តាំង?

**ធី:** ដូចមានតែឌុចហ្នឹង ។

**សុជា:** អញ្ចឹងវាហាក់ដូចខុសពីក្រុមរបស់ពូ ពូថា ពូមិនដែលបានទទួលបញ្ជាផ្ទាល់ពីឌុចម៉ោទេ ពូថាត្រូវឆ្លងកាត់ហ៊ូ, ហ៊ូហ្នឹងអ្នកទទួលពីឌុចម៉ោម៉េចបានម៉ោបែងចែកការងារឲ្យពូធ្វើនៅខាងក្រោមនេះ អញ្ចឹងក្រុមសួរចម្លើយហ្នឹងនៅក្រោមការគ្រប់គ្រងផ្ទាល់របស់ ឌុច?

**ធី:** ឌុច តែហ៊ូ នេះក៏អត់មានសិទ្ធិទៅហៅអ្នកសួរចម្លើយអីដែរ ព្រោះអាណឹងវាតួនាទីផ្សេងគ្នា ។

**សុជា:** គាត់តួនាទីចាប់ចេញចាប់ចូលអី មើលការខុសត្រូវអីនៅក្នុងហ្នឹង?

**ធី:** មើលការខុសត្រូវអង្គភាពហ្នឹងទាំងអស់ ។

**សុជា:** ហើយចង់បានចម្លើយមិនចម្លើយអីអាណឹងខាងក្រុមប៉ុន, ចាន់, ទុយនេះ ។ ហើយចំណែកខាងក្រុមរបស់ហ៊ុយ, ហ៊ុយ ស្រែ នេះគ្រាន់តែតួនាទីមួយយកបាយយកទឹកហូប បន្លែអីផ្គត់ផ្គង់អ្នកធ្វើការនៅក្នុងស-២១ហ្នឹង ។ អញ្ចឹង ប៉ុន, ទុយ អីពូដឹងតួនាទីរបស់គាត់អត់សូវច្បាស់ដែរពូណ៎?

**ធី:** អត់ទេ ។

**សុជា:** ដល់ថ្នាក់ណាថ្នាក់ណា?

**ធី:** ព្រោះអាណឹងយើងមិនអាចក្តាប់បាន ព្រោះគេសុទ្ធតែថ្នាក់កាលណោះគេខ្ពស់ជាឆ្ងាយណា ពួកការពារវាមានអី ។

**សុជា:** តែតួនាទី បើយើងនិយាយថា មិនអាចបញ្ជាគ្នាទៅវិញទៅម៉ោ មានតែឌុចមួយទេណាក្នុងហ្នឹងហ៊ូ នេះក៏មិនអាចម៉ោបញ្ជា ប៉ុន, ចាន់, អី ទុយ ឲ្យធ្វើដែរ, តែបើយើងនិយាយពីឋានៈនៅក្នុងស-២១ហ្នឹង ប៉ុន, ចាន់, ប្អូនទុយនេះមានឋានៈខ្ពស់ៗជាងពួកពូ?

**ធី:** បាទ!

**សុជា:** គេហៅថា ថ្នាក់ដឹកនាំ?

**ធី:** ពួកគេថ្នាក់ដឹកនាំហើយបើនិយាយទៅ គេថ្នាក់សួរចម្លើយគេសុទ្ធតែខ្ពស់ទាំងអស់ ខ្ពស់ជាងការពារ យើងការពារគ្រាន់តែយុទ្ធជនធម្មតាទេ គ្រាន់តែការពារវាមិនអាចរើសយកសមត្ថភាពអីព្រោះបើតួនាទីក្នុងសួរចម្លើយបើនិយាយរួម គឺច្រើនបក្ខជន យើងមិនមែនត្រឹមសម្ព័ន្ធអី ។

**សុជា:** ពូកាលហ្នឹងបានត្រឹមសម្ព័ន្ធទេ?

**ធី:** បាទ!

**សុជា:** មានពីណាផ្សេងទៀតនៅក្នុងក្រុមសួរចម្លើយដែរ?

ធី: ព្រោះក្រុមសួរចម្លើយកាលហ្នឹងខ្ញុំវាមិនដឹងទេ ព្រោះការងារកាលហ្នឹងខ្ញុំមិននិយាយកុហក់ទេ ធ្វើតែការងារខ្លួនឯងធ្វើមិនអស់ផង ហើយគេអត់ឲ្យខ្ញុំទៅណាទេ នៅតែក្នុងហ្នឹងប្រចាំការជាប់រហូតអត់មានទៅណា ហើយការងារយើងហ្នឹងការងារគ្រោះថ្នាក់ បើយើងប្រហេស តែប្រឡំ ចុះអ្នកដែលប្រឡំអីហ្នឹងសុទ្ធតែគ្រោះថ្នាក់ហើយ ប្រយត្ន័តែការងារយើង ។

សុជា: ចុះពូអាចបញ្ជាក់បានពីរឿងការដក ការចម្រេញ អ្នកធ្វើការចាស់ៗដែលម៉ោពីកងពល១២ហ្នឹងត្រូវបានគេដកចេញទៅពេលក្រោយម៉ោទៀតណា៎ អាណឹងវាដោយសារមូលហេតុអីពូបានដឹងទេ?

ធី: ខ្ញុំវាមិនបានដឹងច្បាស់លាស់ទេ ព្រោះអាណឹងវាពិបាកណាស់ ព្រោះអានេះវាផ្សេងគ្នា អានេះបើតាមពិតទៅ ឧបមាថា អ្នកទោសរត់រួចត្រូវចាប់យុទ្ធជនការពារនៅហ្នឹងហើយ ហើយដល់ពេលរ៉ៃគ្នាឈឺទៅចេះតែឆ្លើយ ឆ្លើយទៅចេះតែចាប់ អានេះថាវាពិបាករឿងនេះ វារកយុត្តិធម៌អត់ឃើញ ហើយដល់នេះចេះតែចាប់អញ្ចឹងពិបាកណាស់ អានេះខ្ញុំនិយាយមែនចេះតែនិយាយទេ និយាយទៅតាមការដែលខ្ញុំដឹង ។

សុជា: អញ្ចឹងពូនិយាយម៉ោដល់ករណីនេះ ចាប់ដោយសារយើងធ្វើការ កំហុសនៃការធ្វើការងារ?

ធី: បាទ!

សុជា: ចុះមានអាការចាប់ដែលមានបញ្ជាពីថ្នាក់លើម៉ោ ឧទាហរណ៍ដូចថា គេដឹងថា កងពល១២ហ្នឹងមានគេចាប់តាណាតចាប់អីទៅណា ហើយក្រោយម៉ោគេដឹងថាពួកពូហ្នឹងជាអតីតកងពល១២ដែរគេត្រូវបោសសម្អាតទាំងអស់ អញ្ចឹងអាការចាប់ហ្នឹងគេមានបញ្ជាពីលើម៉ោ ពីខាងសេនាធិការពីខាងមជ្ឈិមអីម៉ោឲ្យចាប់ តើមានព្រឹត្តិការណ៍ហ្នឹងកើតមានឡើងនៅក្នុងកន្លែងពូទេ?

ធី: អានេះខ្ញុំដឹងវាមិនច្បាស់ទេណា បើតាមមើលមាន មែនអត់ទេ ព្រោះខ្ញុំឃើញវរៈសេនាតូចវរៈសេនាធំអីគេចាប់ពីកងពល១២ម៉ោណា គេចង់បោសសម្អាតយើងទៀត ដល់យើងធ្វើនេះគេចេះតែរកលេសហើយ អញ្ចឹងគេចាប់ ។

សុជា: ចុះអ្នកនៅក្នុងមន្ទីរស-២១ហ្នឹងពូមានចាំឈ្មោះទេ អ្នកណាខ្លះដែលត្រូវគេចាប់ដោយសារកំហុសការធ្វើការមិនល្អអី ឬក៏គេចាប់ដោយសារជាប់ពាក់ព័ន្ធខ្សែក្បត់អីលើម៉ោទេ?

ធី: អានេះចាំមិនអស់ទេ ទាល់តែមើលបញ្ជី ។

សុជា: ចុះពូមានចាំម្នាក់ពីរនាក់អី?

ធី: ខ្ញុំអារឿងចាប់ហ្នឹង ខ្ញុំឃើញតែគេចាប់ វាមិនដឹងរឿងពិតប្រាកដរឿងអីៗទេ តែគេចាប់គេអត់ឲ្យយើងដឹងប៉ុន្មានទេ ព្រោះគេចាប់ហ្នឹងមានតែអ្នកសួរចម្លើយទេមានសិទ្ធិទៅយក ហើយចាប់បាន

ដូចថានៅក្នុងមន្ទីរស-២១ហ្នឹង គេចាប់ហើយគេគ្រាន់តែប្រាប់ឈ្មោះឲ្យយើងទេ ដល់ការងារគេអ្នកសួរចម្លើយគេមានសិទ្ធិ ។

**សុជាៈ** ចុះអាយើងចុះបញ្ជីហ្នឹងមានប្រាប់ពីមូលហេតុទេ ចាប់ម៉ោដោយសារមូលហេតុអីៗ មានដែលសរសេរក្នុងក្បាលបញ្ជីទេ?

**ធីៈ** អត់ទេ គ្រាន់តែសរសេរតែឈ្មោះ សរសេរនេះហ្នឹង រឿងសួរមូលហេតុយើងអត់មានសិទ្ធិទេ អ្នកទោសណាក៏ដោយ អត់មានមូលហេតុចាប់ស្អីៗអត់ទេ ព្រោះអាណឹងវាខុសការងារ តែយើងដឹងរឿងអាណឹង អាណឹងវាហួសការងារយើងទៀតហើយ ការងារយើងមែនអ្នកសួរចម្លើយ អត់មានសិទ្ធិសួរអីរឿងចាប់ខុសម៉ោពីអីអត់ទេ ។

**សុជាៈ** ចុះពួកអ្នកធ្វើការជាមួយពូប៉ុន្មាននាក់នៅក្នុងគុកទួលស្លែងហ្នឹងត្រូវគេចាប់?

**ធីៈ** ខ្ញុំមិនអាចដឹងទេ តែបើច្បាស់ច្រើន ព្រោះខ្ញុំដឹងតាំងពីប្រធាន កាលមុនប្រធានវរសេនាតូចមានតាប៉ូច, តាហ៊ូ ។

**សុជាៈ** អត់ទេ អ្នកម៉ោនៅហ្នឹងណា៎, ស-២១?

**ធីៈ** កាលនោះគាត់ក្ដាប់នៅហ្នឹងដែរ ។

**សុជាៈ** គេចាប់ដោយសារមូលហេតុអីពួកគាត់ហ្នឹង?

**ធីៈ** កាលណោះវារួចអ្នកទោសអស់ម្នាក់ពីរនាក់ដែរ ដល់ទៅគេចាប់ទៅ ដល់នេះវាទាក់ទងដល់កងហា, ដល់មេក្រុមដល់អីទៀត ។

**សុជាៈ** ហើយពួកអ្នកទាក់ទងហ្នឹងគេធ្វើម៉េច?

**ធីៈ** ទាក់ទងអី មែនទាក់ទងទេ គេចាប់ណា៎ គេចាប់បន្តអញ្ចឹងណា៎ ។

**សុជាៈ** ហ្នឹងហើយអ្នកដែលទាក់ទងហ្នឹងគេចាប់បន្តចូលហ្នឹងទៀត ឬក៏គេគ្រាន់តែយកទៅរៀនយោបាយ?

**ធីៈ** អត់ទេចាប់បន្តទៀត ។

**សុជាៈ** ដាក់ណាដែរ?

**ធីៈ** ដាក់ហ្នឹងដដែល ។

**សុជាៈ** ដាក់រហូតដល់ពេល ឬក៏គេដាក់បណ្ដោះអាសន្នហើយគេយកទៅដាក់កន្លែងផ្សេងវិញ?

**ធីៈ** អត់ទេ តែនេះហើយអត់មានរស់ទេ ។

**សុជាៈ** ផុតហើយ?

**ធីៈ** ផុតហើយ ខ្ញុំឃើញឲ្យតែហ្នឹងហើយ ផុតហើយ ឲ្យតែចាប់ហ្នឹង ។

**សុជា:** ក្នុងក្រុមពូអីហ្នឹង ឧបមាថា មានអ្នកបងប្អូនពាក់ព័ន្ធនឹងរបបលន់ នល់ នៅតំបន់ខ្ចាំងជំនាន់សង្គ្រាម៥ឆ្នាំហ្នឹងអីណាំ ឬក៏មានបងប្អូនធ្វើការធ្វើអី តើមានគេដក ឬក៏បោសសម្អាតដោយសារបញ្ហាហ្នឹងទេ?

**ធី:** អាណឹងគេដក ព្រោះកន្សែងខ្ញុំហ្នឹង ដែលខ្ញុំម៉ោហ្នឹងវាមិនបានទៅទាក់ទងអីដឹងប្រវត្តិរូបច្រើន ដូចខ្ញុំវាមានពាក់ព័ន្ធរហូត តាំងពីនៅធ្វើសង្គ្រាមណោះ ព្រោះតួនាទីខ្ញុំអត់មានបានស្អីសុទ្ធ ព្រោះគេដឹងប្រវត្តិរូបខ្ញុំវាមិនល្អ បងប្អូន១៧ ហើយចូលធ្វើទាហានបីប្អូនទាក់ណោះ ហើយខ្ញុំមានបានតួនាទីអីសោះ ព្រោះខ្ញុំចូលធ្វើសម្ព័ន្ធហ្នឹងយូរដែរហើយ អាណឹងគេអត់ទាន់មានគោលការណ៍ចំរាញ់ ដល់គេមានគោលការណ៍ចំរាញ់យើងនៅត្រង់ហ្នឹងរហូត ។

**សុជា:** ចុះអត់មានផលអីប៉ះពាល់គេហៅពូទៅរៀន ទៅធ្វើទារុណកម្ម សួរនាំហេតុអីបាន?

**ធី:** អានេះគេគ្រាន់តែអត់យើងមានតួនាទី គ្រាន់តែគេយកយើងម៉ោប្រើ ។

**សុជា:** ចុះអ្នកផ្សេងទៀតក្រៅពីពូ បើសិនជាជាប់ពាក់ព័ន្ធនឹងរឿងរ៉ាវអញ្ចឹងដែរ តើគេធ្វើម៉េច?

**ធី:** អាណឹងក៏គេដកតួនាទី អត់មានតួនាទី គ្រាន់តែសម្រាប់ប្រើ ។

**សុជា:** គេអត់ចាប់ទេ?

**ធី:** អត់ទេ ដូចថា លុះត្រាតែយើង ជួនណារឿងចាប់យើងវាមិនទៀងទេ ដឹងវាមិនច្បាស់ទេ តែបើតាមចាប់ច្រើនតែចាប់តាមខ្សែ ហើយនិងការធ្វើកំហុស ។

**សុជា:** អញ្ចឹងបានន័យថា ការចាប់យកទៅសម្លាប់ដោយសារជាប់និន្នាការពីសង្គមចាស់ ដូចមានបងប្អូនធ្វើទាហាន នៅតំបន់១៧មេសា ហាក់ដូចជាចាប់យកទៅសម្លាប់អត់មានទេ មានតែរឿងចាប់តាមខ្សែក្បត់ ហើយនិងការធ្វើការងារខុស ចុះពីរឿងនេះវិញពូ រឿងដូចថាយើងធ្លាប់បួសរៀនធ្លាប់អី ខាងសាសនាខាងអីវិញ ឧបមាថា មុនធ្វើការអញ្ចឹងពូធ្លាប់បួសរៀនដល់គ្រូសង្ឃរាជរៀនថ្នាក់សាលាបាលី រៀនអីចឹងណាំ ហើយដល់ក្រោយម៉ោពូឈប់ម៉ោធ្វើការអីចឹង ហើយបើកាលណាគេដឹងថាពូធ្លាប់ធ្វើការអញ្ចឹង គេមានសួរនាំ ឬក៏បំពាក់បំប៉ននយោបាយយើងទេ?

**ធី:** អានេះបើតាមខ្ញុំដឹងវាក្នុងអង្គភាពវាមិនទាន់បានដឹងជ្រៅជ្រះទេ វាមិនដឹងប្រវត្តិរូបណាបួសណាអីច្រើនទេ អានេះវាស៊ីសងលើគេអ្នកសរសេរប្រវត្តិរូប ហើយនិងមេគេអ្នកក្តាប់ប្រវត្តិរូបហ្នឹងគេអ្នកចាត់ចែង យើងអត់ដឹង ហើយបើខ្ញុំដូចថាអង្គភាពនៅហ្នឹង ខ្ញុំអត់មានដឹងប្រវត្តិរូបណាណីអីទាំងអស់អត់ដឹងទេ ។

**សុជា:** ចុះមានដែលគេឧស្សាហ៍ម៉ោធ្វើប្រវត្តិរូបពូអីដែរ?

**ធី:** ខ្ញុំដូចមួយឆ្នាំវាឲ្យធ្វើម្តង ។

**សុជា:** អ្នកណាអ្នកធ្វើពូ?

**ធី:** យើងធ្វើខ្លួនយើងឲ្យគេ ។

**សុជា:** ចុះដូចស៊ុយទិតៀនអី ជីវទស្សន៍អី?

**ធី:** អាណឹងគេឲ្យប្រជុំ ម៉ាអាទិត្យប្រជុំម្តង ។

**សុជា:** ហើយមានអ្នកចាប់យកទៅដោយសារតែមូលហេតុដែលការប្រជុំទិតៀនគ្នាអី រិះគន់គ្នាអីទៅវិញទៅមក?

**ធី:** វាមានមែនអត់ទេ ប៉ុនែយើងមិនអាចដឹងច្បាស់ យើងថាចាប់ក៏មិនច្បាស់ ព្រោះអាណឹងជួនកាលការងារគេផ្សេងៗ ដល់ថ្នាក់គេអ្នកបញ្ជាបានដឹង ។

**សុជា:** នៅក្នុងកន្លែងពូហ្នឹងចាប់ដែលរឿងថា ចាប់យកទៅសម្លាប់រឿងពាក់ព័ន្ធនិងរឿងជនជាតិអីមានទេ? ជនជាតិវៀតណាម, ចិន, ចាម កម្ពុជាក្រោមអី?

**ធី:** អ្នកធ្វើការនៅក្នុងស-២១ហ្នឹងហេ៎?

**សុជា:** ហ្នឹងហើយ ។

**ធី:** វាមិនដឹង អត់ដឹងច្បាស់អ្នកណាពាក់ព័ន្ធអារឿងហ្នឹង ។

**សុជា:** ចុះបើអ្នកទោសដែលចាប់ម៉ោពីក្រៅវិញពូដឹងទេ?

**ធី:** អាណឹងយើងអត់ដឹង ព្រោះប្រវត្តិរូបយើងសរសេរដឹងតែនេះ ការងារគេអ្នកសួរចម្លើយ ការងារទាល់តែអ្នកសួរបានដឹង បានដឹងច្បាស់ អ្នកទោសនេះម៉េច អ្នកទោសនោះម៉េចបានដឹងច្បាស់ ។

**សុជា:** ចុះពេលយើងសរសេរបញ្ជីអត់មានដាក់ថាយកម៉ោពីណាអីចឹងៗ?

**ធី:** ដាក់សរសេរជនជាតិ ប៉ុន្តែយើងអត់មានទៅសួរថា អ្នកឯងខុសអីៗ ស្អី យើងគ្រាន់តែសួរថាជនជាតិ បើថាខ្មែរដាក់ខ្មែរ ជនជាតិវៀតណាមដាក់វៀតណាម, ចាមដាក់ចាម ។

## Side B

**សុជា:** នៅក្នុងរបបខ្មែរក្រហមការចាប់មនុស្សយកទៅសម្លាប់ គេដឹងម៉ោគឺថា មានការបញ្ជាពីថ្នាក់លើម៉ោឲ្យចាប់ ទីពីរទៀតដូចថាការចាប់អ្នកធ្វើការនៅក្នុងអគ្គភាពពីស-២១ហ្នឹងមិនចាំបាច់មានការសម្រេចពីថ្នាក់លើម៉ោ ថ្នាក់មជ្ឈិមថ្នាក់អីម៉ោទេ ត្រឹមឌុច ឬក៏ហ៊ួ ចាន់អីហ្នឹងអាចមានសិទ្ធិចាប់អ្នកធ្វើការនៅក្នុងហ្នឹងបាន មួយទៀតគឺថាចាប់ដោយសារយើងធ្វើការជាមួយគ្នាហ្នឹង អ្នកធ្វើការហ្នឹងនិយាយបន្តាច់បន្តុចទៅ រាយការណ៍ទៅលើទៅហើយខាងលើហ្នឹងម៉ោចាប់ តើនៅក្នុងអគ្គភាពរបស់ពូហ្នឹងមានរឿងរ៉ាវបែបហ្នឹងកើតឡើងទេ?

ធី៖ អារឿងចាប់នេះខ្ញុំវាមិនបានដឹងច្បាស់ រឿងអាបន្តូចគ្នា រាយការណ៍ទៅខាងលើដើម្បីឲ្យខាងលើចាប់ ខ្ញុំក៏អត់ដឹង ព្រោះអាការចាប់នេះទាល់តែសម្រេចពីឌុចបានចាប់បាន បើថានេះខ្ញុំមិនដឹងទេ ។

សុជា៖ ចុះពូការចាប់អ្នកនៅក្នុងអង្គភាពហ្នឹងត្រឹមឌុចអ្នកសម្រេច ឬក៏ឌុចទៅសុំយោបល់ពីមជ្ឈិម?

ធី៖ អត់ដឹងដែរ ប៉ុន្តែស្ទីចារម៉ោសុទ្ធតែឌុចហើយ ។

សុជា៖ ឲ្យចាប់អ្នកណាមួយដែលធ្វើខុសធ្វើអីហ្នឹង អាណឹងឌុចហ្នឹងមានចាប់ហ្នង?

ធី៖ មិនដឹង អាណឹងវាមានតែឌុចហ្នឹងសិទ្ធិឲ្យទៅកងសម្រាប់ចាប់ចង់ហ្នឹង ។

សុជា៖ ចុះហ៊ូ អីមានសិទ្ធិចាប់ទេ? ប៉ុនអី?

ធី៖ ហ៊ូតាមខ្ញុំដឹង ហេ៎! វាមិនដឹងច្បាស់ ប៉ុន្តែបើនិយាយសិទ្ធិអញ្ចឹង ព្រោះជីវិតមនុស្សណាវាមែនធម្មតាទេ ទាល់តែគេអ្នក ប៉ុន្តែខ្ញុំមិនដឹងច្បាស់ទេ មិនដឹងជាហ៊ូ មានសិទ្ធិ ឬក៏ប៉ុនមានសិទ្ធិអីចាប់អីខ្ញុំមិនដឹងទេ ប៉ុន្តែព្រោះខ្ញុំមើលរាល់ថ្ងៃ គ្រាន់តែហ៊ូហ្នឹង ពួសុទ្ធតែឌុចហ្នឹងគេទៅហៅម៉ោម្តងៗខ្លាច ។

សុជា៖ ពេលដែលពូមើលឃើញសកម្មភាពកាលនៅក្នុងស-២១ហ្នឹងហេ៎?

ធី៖ បាទ! គ្រាន់តែពួគេគេហៅមានការអីត្រូវទុក ត្រូវប្រញាប់ទៅដែរ មែនដូចថាយើងមានតួនាទីស្មើរសមាជិកគេហើយយើងចេញបានទេ តែព្រោះអានេះមនុស្សយើងម្នាក់ៗខ្លាចរឿងជីវិតហ្នឹងហ្នង ព្រោះវាចាប់ដូចងាយណាស់ បានខ្ញុំពិបាកណាស់រឿង ហើយខ្ញុំហ៊ូគ្រាន់តែឃើញមុខខ្ញុំមិនហ៊ានមើលមុខផង និយាយត្រង់ ។

សុជា៖ ខ្លាចគ្នាពីដំណាក់ៗហ្នឹងខ្លាចហ្នង?

ធី៖ ខ្លាចហ្នង ។

សុជា៖ ចុះប៉ុន អំណាចរបស់ប៉ុនហ្នឹងយ៉ាងម៉េចដែរនៅក្នុងស-២១?

ធី៖ អត់ទេអាណឹងផ្នែកសួរចម្លើយគេផ្សេង គេនៅផ្ទះក្រៅនោះ ខ្ញុំនៅក្នុងគុកនេះ ។

សុជា៖ ចុះពូពេលដែលគេចាប់អ្នកដែលនៅក្នុងស-២១ហ្នឹងពូមានដែលឃើញមានចំណារឬក៏មានសំបុត្រស្នាមអីយកទៅ ពេលចាប់ហ្នឹងមានកាន់សំបុត្រកាន់អីយកទៅដែរអត់?

ធី៖ យកឲ្យណាគេ?

សុជា៖ ឲ្យអ្នកដែលត្រូវចាប់ខ្លួនយកទៅដាក់គុក ។

ធី៖ ខ្ញុំអត់បានដឹងអារឿងចំណារចារហ្នឹង ដឹងតែគេចាប់ពីក្រៅម៉ោយកម៉ោចូលហ្នឹងហ្នង ។

សុជា៖ ប៉ុនអ្នកដែលធ្វើការនៅក្នុងស-២១ហ្នឹង មិនមានគេចាប់ដែរ ចុះអ្នកដែលត្រូវគេចាប់ហ្នឹងមានគេចារ ឬយ៉ាងម៉េចដែរមុននឹងគេចាប់យកទៅ?

**ធី:** ខ្ញុំអត់បានដឹងច្បាស់ ព្រោះអាណឹងការងារគេផ្សេងពីយើងនោះ មិនដឹងជាគេចាប់ហ្នឹងគេចារឲ្យក៏មិនដឹង ។

**សុជា:** ជំនាន់នោះពូពេលដែលចាប់មនុស្សអី ចាប់អ្នកដែលធ្វើខុសម្តងៗ កាលហ្នឹងពូមានដឹងថាគេចាប់តាមរបៀបណា ដូចថាមានពីថ្នាក់លើម៉ោគេឲ្យចាប់ ឬក៏អ្នកនៅក្នុងកន្លែងហ្នឹងគេមានសិទ្ធិសម្រេចចាប់ហ្នឹង ឬយ៉ាងម៉េច?

**ធី:** អាកន្លែងហ្នឹងខ្ញុំអត់បានដឹងច្បាស់ដែរ មិនដឹងជាគេដឹងថាគេចង់ចាប់មនុស្សហ្នឹង គេរាយការណ៍ទៅលើ ហើយលើសម្រេចឲ្យម៉ោក៏មិនដឹង អីក៏គេសម្រេចខ្លួនគេក៏មិនដឹង មិនដឹងពិតប្រាកដទេអាណឹង ។

**សុជា:** ចុះអ្នកធ្វើការជាមួយគ្នាដូចជាពូនៅកន្លែងកត់បញ្ជី ឬក៏នៅក្នុងកងការពារហ្នឹង អ្នកដែលធ្វើការជាមួយគ្នាហ្នឹងដូចថាពេលដែលយើងធ្វើការទៅឃើញអ្នកផ្សេងមានកំហុសអីចឹងគេមានរាយការណ៍ឡើងទៅលើឲ្យម៉ោចាប់អ្នកដែលខុសហ្នឹងដែរឬក៏អត់?

**ធី:** អាណឹងខ្ញុំអត់បានដឹងដែរ ព្រោះអាណឹងដូចថានៅក្នុងកងការពារអញ្ចឹងគេមានមេក្រុមគេនៅខាងក្រៅនោះទេ ខ្ញុំនៅតែខាងក្នុងអត់សូវក្តាប់បានអារឿងអញ្ចឹងៗ ។

**សុជា:** ចុះពូកាលជំនាន់ហ្នឹងពូដែលពូភ្នាក់ងារសេ.អ៊ី.អា កា-ហ្សេ-បេ ឬក៏យ៉ាងម៉េចៗដែរគេត្រូវចាប់ណាពូ?

**ធី:** អានេះទាល់តែខាងសួរចម្លើយបានគេដឹងច្បាស់ ខ្ញុំអ្នកទោសម៉ោដឹងតែកត់ហ្នឹងចេញចូលហើយយើងហួសតួនាទីក៏យើងអត់ហ៊ានធ្វើដែរ ។

**សុជា:** ហើយពូពេលដែលពូកត់បញ្ជីកត់អីហ្នឹងអ្នកទោសហ្នឹងប្រភេទអ្នកទោសហ្នឹងយ៉ាងម៉េច អ្នកទោសហ្នឹងខុសយ៉ាងម៉េចត្រូវចាប់ពីកន្លែងណា ចាប់ថ្ងៃណា គាត់ហ្នឹងខុសយ៉ាងម៉េចចូលសេ.អ៊ី.អាក្បត់យ៉ាងម៉េចៗមានសរសេរដាក់ទេ?

**ធី:** អត់ទេក្នុងហ្នឹងអត់មាន ប្រវត្តិរូបអត់មានសរសេរអីអ្នកទោសហ្នឹងខុសអី ឬក៏សេ.អ៊ី.អា ឬក៏ជាកា-ហ្សេ-បេ អីអត់មានទេ សរសេរហ្នឹងគ្រាន់តែដាក់ឈ្មោះ អាយុ ជាតិ និងសញ្ជាតិ ហើយ របបររកស៊ី ឪពុកម្តាយ ហើយមានកូនប៉ុន្មាននាក់ ចាប់ថ្ងៃទីប៉ុន្មាន ហើយចាប់យកម៉ោពីណា ដូចថាម៉ោពីភូមិភាគណាតែប៉ុណ្ណឹងទេ ព្រោះអាការងារផ្ទៃក្នុងគេអត់ឲ្យយើងដឹងទេ ។

**សុជា:** ចុះដូចថារបៀបពូកត់បញ្ជីហ្នឹងយ៉ាងម៉េច គេបញ្ជូនឯកសារម៉ោឲ្យពូចម្លងតាម ឬក៏អ្នកទោសហ្នឹងម៉ោដល់កន្លែងពូ ឲ្យពូសួរគេ ពូសរសេរដាក់ក្នុងបញ្ជីហ្នឹង ឬក៏ឯកសារគេម៉ោ?

**ធី:** អត់មានឯកសារម៉ោទេ, ដឹងតែអ្នកទោសគេម៉ោ យើងដឹងតែកត់តាមគំរូដែលគេធ្វើឲ្យហ្នឹង អាគំរូប្រវត្តិរូប ខ្ញុំសួរតែតាមអាគំរូគេធ្វើឲ្យហ្នឹង ។

**សុជា:** ដូចថាអ្នកទោសដែលម៉ោដល់កន្លែងពូហ្នឹង ពូសួរអ្នកទោសថាឈ្មោះអី អាយុប៉ុន្មាន អីក៏ធ្វើការនៅកន្លែងណា មានឪពុកម្ដាយឈ្មោះអី ម៉ោពីអង្គភាពណា ពូសួរផ្ទាល់ទៅអ្នកទោសហ្នឹងហ្នង?

**ធី:** បាទ! សួរហើយ ខ្ញុំយកដាក់តែប៉ុណ្ណឹងទេ ។

**សុជា:** កាលហ្នុងពេលដែលពូកត់បញ្ជី ពូសួរនាំហ្នឹង ពូនៅចាំថាធ្លាប់សួរធ្លាប់អីពីណាខ្លះទេ? សួរអ្នកទោសដែលពូត្រូវកត់ឈ្មោះដែលចូលក្នុងបញ្ជីណា៎ តើមានអ្នកណាដែលពូនៅចាំថា លក្ខណៈពិសេសអីដូចថា ជនជាតិ អ្នកធំអីណា៎ពូ ពូនៅចាំដែរអត់?

**ធី:** បើនិយាយពីរឿងអ្នកធំវិញយើងអត់មានបានទៅកត់ទេ អាណឹងខាងសួរចម្លើយគេយកម៉ោយកចូលក្នុងបន្ទប់ហើយ ។

**សុជា:** ចុះអ្នកធំយើងកត់បញ្ជីឈ្មោះគេកត់ធ្វើម៉េចទៅ?

**ធី:** កត់រហូតគេឲ្យឈ្មោះម៉ោ ប៉ុន្មាននាក់ អត់ឲ្យដឹងយើងម៉ោនរណាទេ ដឹងតែប៉ុណ្ណឹង ។

**សុជា:** អញ្ចឹងដូចអ្នកធំអី ពូមិនដែលបានជួបសួរនាំអីទេ?

**ធី:** អត់ទេ ។

**សុជា:** អាណឹងយើងគ្រាន់តែគេឲ្យបញ្ជីម៉ោវិញ?

**ធី:** ហ្នឹងហើយ គេឲ្យបញ្ជីម៉ោវិញ ។

**សុជា:** ចុះចំពោះដូចជាអ្នកខាងទាហានខាងអី ដូចខាងកងទ័ព កាលជំនាន់ហ្នឹងមានវ៉ៃនៅព្រំដែនខាងវៀតណាមអី, កាលហ្នឹងមានចាប់បានទាហានវៀតណាមដាក់ចូលក្នុងគុកទួលស្លែងទេកាលហ្នុង? ពូមានដូចថាបានជួប បានឃើញ ហើយបានកត់ឈ្មោះដែរអត់?

**ធី:** អាណឹងមិនដឹងជាបានកត់ មិនបានកត់ខ្លះ ជួនណាអាខ្លះដែលវាមិនចាំបាច់ច្រើនឲ្យបញ្ជីម៉ោយើងគ្រាន់តែចូលបញ្ជីឲ្យគ្រប់ចំនួនរបស់គេ ។

**សុជា:** ចុះកាលហ្នុងពូមានបានឃើញផ្ទាល់ភ្នែក ដែលគេចាប់ទាហានវៀតណាមដែលគេវ៉ៃបានហើយ ហើយគេចាប់បាន ហើយគេយកម៉ោចូលក្នុងគុកទួលស្លែងពូមានដែលបានឃើញផ្ទាល់ដែរអត់?

**ធី:** អត់បានផ្ទាល់ទេអាណឹង ច្រើនតែពួកចាប់នៅកំពង់សោម កំពង់អី ពួកវៀតណាមដែលឆ្លងដែនឆ្លងអី ។

**សុជា:** អាណឹងចាប់បាន?

**ធី:** អាណឹងច្រើនមន្ទីរយកម៉ោ ។

**សុជា:** ពួកឆ្លងដែនហ្នឹង ពួកហ្នឹងជាទាហាន ឬក៏ជាប្រជាជន?

**ធី:** ប្រជាជនឆ្លងដែនទៅថៃ ។

**សុជា:** ឆ្លងដែនពីស្រុកយួនទៅថៃ?

ធី៖ ទៅថៃ ទៅប្រទេសទីបី ។

សុជា៖ ដល់ពេលចាប់បានគេយកម៉ោដាក់គុកទួលស្លែងដែរ?

ធី៖ បាទ!

សុជា៖ កាលហ្នុងច្រើនដែរអត់ពូបើតាមពូចាំ?

ធី៖ មិនច្បាស់ដែរ ទាល់តែមើលបញ្ជី ខ្ញុំវាភ្លេចអស់ហើយ វាច្រើនពេកមិនដឹងអ្នកណាជាអ្នកណា ។

សុជា៖ មានស្រីមានប្រុស មានចាស់មានក្មេងអីចឹងក៏ម៉េច?

ធី៖ បាទ! មានស្រីមានប្រុស មានចាស់មានក្មេង ។

សុជា៖ ដូចថាកាលហ្នុងអ្នកទោសវៀតណាមអញ្ចឹងចូលម៉ោដល់កន្លែងពូឈរឲ្យពូសួរនាំ កត់ឈ្មោះក្នុងបញ្ជីដែរអីក៏ម៉េច?

ធី៖ គ្រាន់សួរឈ្មោះគេតែប៉ុណ្ណឹង ហើយរឿងនេះយើងស្តាប់អត់បាន បើដឹងតែចំនួន ។

សុជា៖ ចុះឈ្មោះដូចថាក្នុងហ្នឹងខ្ញុំធ្លាប់មើលបញ្ជីក្នុងទួលស្លែងហ្នឹងដែរ ឧបមាថាឈ្មោះងៀន វ៉ាន់សឿន អីចឹង មានអាយុប៉ុន្មាន ម៉ោពីភូមិណា មានតួនាទីស្អី ចាប់ថ្ងៃណា ចាប់នៅកន្លែងណា ខ្ញុំធ្លាប់មើលឃើញអញ្ចឹងដែរ?

ធី៖ អាណឹងគេឲ្យបញ្ជីម៉ោ ។

សុជា៖ ចុះកាលហ្នុងពូដឹងថា មានអ្នកប្រែ មានអ្នកចេះវៀតណាម ចេះយួនអីដើម្បីសួរចម្លើយដើម្បីអីនេះហ្នឹងមានអ្នកសួរអញ្ចឹងមែនទេនៅទួលស្លែង?

ធី៖ អាណឹងបែបមានតាមមើល ព្រោះអ្នកសួរកាលនេះ គេប្រគល់ទៅខាងខុចហ្នឹង ព្រោះអ្នកសួរវាច្រើនដែរណ៎ា តែនេះគេរើសអ្នកសួរខាងវៀតណាមហើយ ។

សុជា៖ ពូមានស្គាល់ឈ្មោះអ្នកសួរខាងវៀតណាមហ្នឹងដែរអត់?

ធី៖ អត់, មិនសូវដឹងទេ ច្រើនណាស់ ។

សុជា៖ អ្នកទោសខាងវៀតណាមអីហ្នឹងណ៎ា ពូមានចាំឈ្មោះពីណាម្នាក់អីដែរអត់?

ធី៖ អត់ចាំច្បាស់ទេ មិនដឹងជាខុចហ្នឹងឲ្យចាន់ ឲ្យប៉ុន គេចាត់តាំងកម្លាំងគេណាឲ្យសួរខ្ញុំអត់បានដឹងច្បាស់ទេ ។

សុជា៖ ប៉ុនកាលហ្នុងពូអត់ដឹងថាអ្នកណាចេះវៀតណាមនៅក្នុងហ្នឹងសម្រាប់សួរចម្លើយទេ ឬក៏ពីណា ដូចប៉ុន អីគាត់ចេះវៀតណាមគាត់សួរខ្លួនឯង ឬក៏មានអ្នកផ្សេងទៀត?

ធី៖ មិនដឹងច្បាស់ ព្រោះអាការផាររហ្នឹងខ្ញុំវាអត់ចាប់អារម្មណ៍ ព្រោះអាការផាររវាខុសពីការផាររឯងវាគិតរឿងប្រយ័ត្នបំផុតតែពីរឿងការផាររឯង ចង់ពីណាធ្វើអីធ្វើទៅ ខ្ញុំមិនឈឺក្បាល ។

សុជា៖ ពូដែលឃើញគេសួរចម្លើយអ្នកទោសទេ?

ធី៖ សួរចម្លើយអ្នកទោស អាណឹងក្រៅទេ យើងអត់មានសិទ្ធិចូលទេ ។

សុជា៖ ចុះពូដូចថា អ្នកទោសវៀតណាមហ្នឹង ពេលដែលចូលទៅហ្នឹងគេកត់បញ្ជីចូល ពេលដែលយកទៅកម្ទេចយើងកត់ចេញហ្នឹងគេឲ្យបញ្ជីម៉ោវិញ ឬក៏អ្នកទោសយកចេញម៉ោយើងកត់ពេលដែលយកទៅកម្ទេចហ្នឹង?

ធី៖ គេឲ្យបញ្ជីវិញដដែល ព្រោះកម្ទេចក៏ដោយ ចូលក៏ដោយ សំខាន់កម្ទេចគេសុទ្ធមានឈ្មោះគេពីណោះហើយ ។

សុជា៖ អញ្ចឹងគេឲ្យបញ្ជីម៉ោយើងចម្លងតាម?

ធី៖ ចម្លងតាម ។

សុជា៖ អ្នកទោសដែលខាងវៀតណាមដែលគេយកម៉ោដក់គុកទួលស្លែងអីហ្នឹង បើតាមពូចាំប្រហែលរយៈប៉ុន្មានទៅបានគេយកទៅកម្ទេច?

ធី៖ អាណឹងអត់ទៀង ស្រេចតែលើការងារអ្នកសួរចម្លើយគេធ្វើការ ខ្ញុំអត់ដឹង ។

សុជា៖ ប៉ុនដូចថា ពូនៅចាំអញ្ចឹង ពូធ្វើការនៅកន្លែងកត់បញ្ជី នៅមាត់ទ្វារឬក៏នៅកន្លែងណា?

ធី៖ នៅមាត់ទ្វារចេញចូល ។

សុជា៖ ដូចថាពូចំណាំថា អ្នកទោសវៀតណាមហ្នឹងពេលចូលទៅឆ្លងកាត់តាមទ្វារហ្នឹង ពេលដែលគេយកទៅកម្ទេចគេក៏យកឆ្លងកាត់តាមទ្វារហ្នឹងដែរ?

ធី៖ បាទ!

សុជា៖ កាលហ្នឹងពូមានចាំថា គេចូលទៅហើយគេយកទៅវិញហ្នឹង ដូចថារយៈពេលប៉ុន្មានដែរ?

ធី៖ អានេះវាអត់ទៀង បើនិយាយទៅវាអត់ដឹងច្បាស់ ព្រោះយើងវាអត់សូវចាប់អារម្មណ៍ យើងគិតតែពីរឿងធ្វើបញ្ជីហ្នឹងថាថ្ងៃណាដែលគេសម្រេចពីណោះម៉ោយើងធ្វើអាណឹងទៅ យើងអត់បានចាប់អារម្មណ៍ថា អ្នកហ្នឹងទើបតែចូលហើយ បីបួនថ្ងៃគេយកទៅចេញយើងអត់ចាប់អារម្មណ៍អញ្ចឹង ព្រោះមនុស្សច្រើនណាស់ក្អាប់អត់ដឹងទេ បើអូនឯងធ្វើហ្នឹងបានវង្វេងហ្មង ។

សុជា៖ ពូនៅកន្លែងអង្គភាពពូហ្នឹង ឧទាហរណ៍អ្នកដែលចាត់ទុកថាអ្នកចេះដឹង បញ្ញាវ័ន្ត ដូចអ្នកដែលមានចំណេះវិជ្ជាខ្ពស់ដូចពូអីរៀនដល់បាក់អង់ហ៊ឺ អីក៏បាក់ឌុប?

ធី៖ ទេ, ទើបតែប្រលងបាក់អង់ទេ ។

សុជា៖ ចុះគេនៅក្នុងអង្គភាពអីហ្នឹង គេមានចាត់ការស្នូរនាំ ឬក៏ស្រាវជ្រាវរកអ្នកណាដែលចេះជាងគេ គេដកដោយចាត់ទុកថា សមាសភាពមិនល្អអីទេ នៅក្នុងអង្គភាពហ្នឹង?

ធី៖ អាណឹងគ្រាន់ដូចថា បើនិយាយ ក្នុងប្រវត្តិរូបសម័យហ្នឹង ក្នុងសម័យបដិវត្តហ្នឹង បើយើងរៀនចេះដឹងគេដាក់វណ្ណៈអនុធនសិស្សហើយ ។

សុជាៈ ចុះពូជាក់អញ្ចឹងដែរ?

ធីៈ បាទ ។

សុជាៈ តែគេមានធ្វើអីទេ គេមានចំរាញ់វណ្ណៈហ្នឹងទេ?

ធីៈ ចំរាញ់ប៉ះច្រើនដែរ ប៉ុន្តែខ្លះគេទុកឲ្យបម្រើការងារគេទៀតទុកទៅ ។

សុជាៈ មិនទាន់មានអ្នកជំនួសបាន?

ធីៈ ហ្នឹងហើយ ។

សុជាៈ តែបើសិនជាមានអ្នកជំនួសដៃជំនួសជើងបានប្រហែលជាគេដកដែរអីក៏ម៉េច?

ធីៈ ខ្ញុំដឹងតែប្រសិនបើជំនួសដៃជំនួសជើងបានទៅបាត់ទៀតហើយ ។

សុជាៈ ចុះអ្នកផ្សេងពីពូដែលជាអ្នកចេះដឹងរៀនបានជ្រៅជ្រះ សរសេរ ស្តាប់បារាំងអី កាលហ្នឹងយើងអាចសរសេរបារាំងហើយបាក់អង់អី យើងសរសេរបានបន្តិចបន្តួចអីចឹង បើមានអ្នកផ្សេងអីទៀតក្រៅពីពូដែលត្រូវគេចាប់ដោយសាររឿងរៀនរឿងសូត្រអញ្ចឹង?

ធីៈ កាលហ្នឹងនៅក្នុងអ្នកធ្វើការហ្នឹងវាអត់សូវមានអ្នកចេះប៉ុន្មានទេ ព្រោះសុទ្ធតែម៉ោពីទ័ពទាំងអស់ហ្នឹង ហើយទ័ពរើសម៉ោបម្រើការងារហ្នឹង ហើយខ្ញុំចូលនេះដោយសារគេឃើញខ្ញុំចេះសរសេរអក្សរ ហើយខ្ញុំអ្នកធ្វើបញ្ជីនៅវរសេនាតូចកាលសង្រ្គាមផង ហើយនេះគេឃើញខ្ញុំធ្វើបញ្ជីផង ហើយខ្ញុំកាលមុននៅជាមួយ ហ៊ុយ ស្រែ គាត់បញ្ជាការវរសេនាតូចខ្ញុំ ដល់ពេលគេរៀបជាអគ្គភាពអញ្ចឹងទៅ កាលមុនមិនហៅស-២១ទេ វារបស់សេនាធិការ ។

សុជាៈ កាលមុននៅកន្លែងដាំផេងនោះ?

ធីៈ នៅកន្លែងដាំផេង ។

សុជាៈ នៅកន្លែងក្រោយពេទ្យមុន្នីវង្សហេ៎?

ធីៈ បាទ!

សុជាៈ ចុះអាណឹងធ្វើពីហ្នឹងម៉ោឆ្នាំណា?

ធីៈ ចូល៧៦ជាងហើយ ។

សុជាៈ មូលហេតុអីបានរើពីណោះ?

ធីៈ មិនដឹងយ៉ាងម៉េច ក្រែងខាងលើគេចាត់តាំង ។

សុជាៈ រើម៉ោទាំងអស់ហ្នឹង ខាងណោះលែងមានហើយ?

ធីៈ បាទ!

សុជាៈ កាលហ្នឹងនៅណោះឌុច អត់មានតួនាទីទេកាលនៅមុំក្រោយពេទ្យមុន្នីវង្សនៅដាំផេងហ្នឹងណា៎?

ធីៈ កាលហ្នឹងដូចអត់ឃើញ ដូចម៉ោម៉ាក្អេតហើយតាមមើល វាចាំមិនច្បាស់ ។

**សុជាៈ** ពូដឹងថាខុចហ្នឹងចេញពីខាងណាម៉ោ ពីអន្តភាព, កងពលណា?

**ធីៈ** មិនច្បាស់សោះ ព្រោះអាណឹងខ្ញុំនិយាយត្រង់ បានត្រឹមតាណាតនេះយើងលែងចង់ដឹងហើយ ធំណាស់ ថ្នាក់កងពល ហើយចុះនិយាយត្រឹមតាណាតគាត់ចង់ខ្លាចខុចទៀតហើយ ដូច្នេះគេធំ មែនទែនហើយ ។

**សុជាៈ** តាណាតខ្លាចខុច?

**ធីៈ** ហ្នឹងហើយក៏ខ្លាចខុចដែរ គាត់ថ្នាក់កងពលមិនធម្មតាទេ ហើយខ្លាចខុច ខ្ញុំគ្រាន់តែឃើញអត្តចរិក ដែលនេះអីទេណា ហើយហ្វូនេះខ្លាចតាណាតជាងអីទៀត ព្រោះអ្នកកងពល អ្នកវរសេនាតូច វាតួនាទីវាខុសគ្នាឆ្ងាយណាស់ ព្រោះគេអ្នកកងពលគេមានសិទ្ធិដកគេមានសិទ្ធិអីទាំងម៉ាចប់ ហើយ ទំរាំតែតាណាតចង់ខ្លាចតាខុចទៀតហើយ មិនដឹងយើង មួយថ្ងៃៗបុណ្យកុំឲ្យតែតាហ្វូ ខ្ញុំនិយាយ ត្រង់កុំឲ្យតែព្រួសូរគាត់ហៅទេ ចេះតែខំធ្វើៗទៅ ខ្លាចតែហៅមានការអីទេ ។

**សុជាៈ** ចុះពូដូចខុច អីដែលឃើញខុចហ្នឹងទាក់ទងជាមួយមេដឹកនាំធំៗផ្សេងទៀតទេ?

**ធីៈ** ការងារនេះខ្ពស់ណាស់ ខ្ញុំអត់ដឹងទេ ។

**សុជាៈ** ឬក៏មានដែលឃើញអ្នកដឹកនាំធំៗហ្នឹងដែលម៉ោ ដូចខៀវ សំផន, អៀង សារី, ប៉ុល ពត, សុន សេនអី នួន ជា អីមានដែលម៉ោ?

**ធីៈ** អត់ទេ កន្លែងគុកអត់មាន ។

**សុជាៈ** អាណឹងបើថាទៅ ការសហការណ៍គ្នាក្រែងលោកបែងចែកអំណាច ដូចថាខុចហ្នឹងពេលដែលចាប់ ម៉ោគ្រប់គ្រងមើលអ្នកទោសអ្នកអីហ្នឹងទៅ ឬក៏ពួកហ្នឹងម៉ោទស្សនៈកិច្ច ឬក៏មើលការខុសត្រូវ ដល់ក្នុងគុក?

**ធីៈ** ដល់ក្នុងគុកអត់មានទេ ។

**សុជាៈ** ហើយអាការទាក់ទងសំបុត្រស្នាមគ្នាទៅវិញទៅមក?

**ធីៈ** មានតែគេណោះ ព្រោះខុចមែនផ្ទះនៅហ្នឹងទេណា នៅផ្លូវធំមុន្នីវង្សណ៍ ។

**សុជាៈ** ចុះពូដែលឃើញអ្នកធំអស់ហ្នឹងទៅផ្ទះខុចទេ? ឬក៏ខុចអីទៅទាក់ទងពួកហ្នឹងនៅកន្លែងណា?

**ធីៈ** ខ្ញុំមិនដឹងទេ ការងារគេធំៗ ខ្ញុំមិនហ៊ានទេ ។

**សុជាៈ** ចុះពូគិតថា ពូនិយាយមុនដំបូងថា អ្នកដែលធ្វើខុសនៅក្នុងគុកទួលស្លែងហ្នឹងខុចមានសិទ្ធិចាប់ ចុះ ពូគិតថា ការចាប់អ្នកទោសពីក្រៅម៉ោមានការជាប់ពាក់ព័ន្ធនឹងខុចដែរឬយ៉ាងម៉េច ឧទាហរណ៍ថា សួរចម្លើយអញ្ចេះ ឧបមាថាខុចចាប់អឿនដែលប្រធានកងពល៣១០នៅឧត្តរណ៍ពូ ចាប់អឿន ម៉ោ អឿនហ្នឹងឆ្លើយដាក់ថាអ្នកណាមួយនៅក្រោមបញ្ជារបស់អឿនហ្នឹង ឧបមាថាឈ្មោះ ជន អីចឹងណ៍ អញ្ចឹងពេលដែលខុចសួរចម្លើយអឿននេះទៅបានន័យថាចេញឈ្មោះជនមួយទៀត

ហើយដែលជាមុខសញ្ញានៃការចាប់ហ្នឹង អញ្ចឹងឌុចហ្នឹងមានសិទ្ធិបញ្ជាកងការពាររបស់ខ្លួនទៅចាប់ដនហ្នឹងម៉ោតែម្តងឬក៏ឌុចហ្នឹងគ្រាន់តែមានសិទ្ធិបញ្ជូនឈ្មោះទៅឲ្យថ្នាក់មជ្ឈិមលើនេះសម្រេចចាប់ដនទៀត?

**ធី:** អានេះខ្ញុំដឹងវាមិនច្បាស់ទេ ប៉ុន្តែបើតាមគោលការណ៍ឌុចគាត់ក៏អត់មានសិទ្ធិទៅចាប់អញ្ចឹងដែរ ទាល់តែមាន អានេះតាមការស្មានរបស់ខ្ញុំទេណា វាមិនមែនទៅចាប់រំលងអញ្ចឹងបានទេ ទាល់តែទៅខាងលើហើយ ។

**សុជា:** តែបើនៅក្នុងគុកទួលស្លែងហ្នឹងឌុចមានសិទ្ធិទាំងអស់?

**ធី:** បើនៅក្នុងគុកទួលស្លែងហ្នឹងបើតាមខ្ញុំសន្និដ្ឋានឌុចមានសិទ្ធិ តែទោះមានសិទ្ធិក៏ត្រូវរាយការណ៍ទៅលើដែរ បើមានសិទ្ធិហើយសម្រេចចាប់បានទេ ។

**សុជា:** តែចាប់ហើយបានរាយការណ៍! ឬក៏រាយការណ៍ហើយបានចាប់ បើតាមពូសន្និដ្ឋាន?

**ធី:** បើខ្ញុំសន្និដ្ឋានទាល់តែរាយការណ៍មុន ធ្វើអីទាល់តែរាយការណ៍មុន ។

**សុជា:** រាយការណ៍ការមុនបានមានសិទ្ធិចាប់?

**ធី:** បាទ!

**សុជា:** ឥឡូវឧទាហរណ៍ថាចាប់ មិត្តភ័ក្ត្ររបស់ពូម្នាក់ធ្វើឲ្យអ្នកទោសរួច ឬក៏សម្លាប់ខ្លួន អញ្ចឹងកំហុសមិនចាំបាច់រាយការណ៍ទៅថ្នាក់មជ្ឈិមទេហ៎ ឌុចហ្នឹងមានសិទ្ធិចាប់អ្នកហ្នឹងហ្មង?

**ធី:** អានេះខ្ញុំដឹងវាអត់ច្បាស់ទេ ប៉ុន្តែការងារធ្វើអីទាល់តែរាយការណ៍ទៅលើសិនបានធ្វើចេញរួច ។

**សុជា:** ព្រោះជួនកាលការងារខ្លះវាបន្ទាន់ដែរយើងអ្នកនៅក្នុងអង្គភាពហ្នឹង ប្រធានអង្គភាពហ្នឹងសម្រេចហើយបានសុំរាយការណ៍ជូនទៅថ្នាក់លើវិញ?

**ធី:** អានេះខ្ញុំដឹងអត់ច្បាស់ដែរ ។

**សុជា:** ចុះពូនៅក្នុងអង្គភាពរបស់ពូថាឥឡូវត្រូវតែធ្វើជីវទស្សន៍ ឧទាហរណ៍ថាការធ្វើជីវទស្សន៍ហ្នឹងគេត្រូវតែប្រាប់ថាអ្នកដែលមានជាប់គេញជាកា-ហ្សេ-បេ, ជាសេ.អ៊ី.អា គេត្រូវតែចាប់ដែរ គេមានប្រាប់អញ្ចឹងទេ អីក៏អត់ទេ?

**ធី:** យើងធ្វើជីវទស្សន៍កន្លងម៉ោច្រើនតែធ្វើពីការងារគុណសម្បត្តិ គុណវិបត្តិដែលយើងធ្វើហ្នឹងប៉ុណ្ណឹង អារឿងប៉ះពាល់ទៅលើរឿងថា អាណឹងវាដូចអត់ដែល ។

**សុជា:** ចុះមានរឿងគោលនយោបាយនៅក្នុងអង្គភាពរបស់ពូហ្នឹងមានគោលនយោបាយ ឲ្យចំរាញ់ ឲ្យតាមដានស្រាវជ្រាវរកភ្នាក់ងារកា-ហ្សេ-បេ, ជាសេ.អ៊ី.អា ភ្នាក់ងារយួន ឬក៏អ្នកដែលធ្លាប់ជាអនុធនសិស្ស ជាគ្រូបង្រៀនជាអី នៅក្នុងអង្គភាពរបស់ពូហ្នឹងទេ?

ធី៖ គេមិនសួរឲ្យតាមដានអញ្ចឹងទេ ព្រោះអានេះការងារគេឲ្យធ្វើយ៉ាងម៉េចម្នាក់ៗឲ្យខំការងាររៀងខ្លួន ។

សុជា៖ មិនសួរបានន័យថាមាន ឬក៏អត់មាន?

ធី៖ តាមខ្ញុំសន្និដ្ឋានអាណឹងខ្លួនខ្ញុំ តែបើគេក្រែងអគ្គភាពក្នុងក្រុមក្នុងអីគេ គេមានគោលការណ៍គេម៉េចអីខ្ញុំអត់ដឹងទេ ព្រោះខ្ញុំវានៅដាច់ដោយឡែកពីគេ មែននៅក្នុងអគ្គភាពណា៎ ។

សុជា៖ ចុះពូគិតថាអ្នកដែលត្រូវគេចាប់ដាក់ទួលស្លែងទាំងអស់ត្រូវគេយកទៅសម្លាប់មែនឬក៏មិនមែន?

ធី៖ អាណឹងគេយកទៅសម្លាប់មែនហ្នង ។

សុជា៖ សម្លាប់នៅណាពូ?

ធី៖ ស្រេចតែទៅលើកងការពារ នៅបឹងជើងឯងអី ស្រេចតែគេយកចេញទៅក្រៅអាណឹង ។

សុជា៖ ចុះនៅក្នុងហ្នឹង?

ធី៖ ក្នុងហ្នឹងយើងក៏មិនអាចដឹងដែរ អាណឹងស៊ីសងទៅលើប្រធានកងការពារគេចាត់ចែង ។

សុជា៖ ចុះពូមានហេតុផលអីបានពូហ៊ានអះអាងថាអ្នកទោសទាំងអស់ហ្នឹងត្រូវគេយកទៅសម្លាប់?

ធី៖ ព្រោះគេចារម៉ោថាកម្ទេច បើកម្ទេចបានន័យថាសម្លាប់ហើយ អានេះចារលើក្រដាស់ដាក់អញ្ចឹងហើយ ។

សុជា៖ អ្នកទោសដែលយកចេញពីហ្នឹងហើយ ដាក់ថាកម្ទេចហ្នឹង?

ធី៖ កម្ទេចហើយ ត្រូវតែស្លាប់ហើយ ព្រោះមែនគេចារថាឲ្យដកចេញ ឲ្យទៅរៀនសូត្រទៅអីណាអត់ផងហ្នឹង តែគេចារដាក់សរសេរម៉ោថាកម្ទេច ។

សុជា៖ គេចារ, គេហ្នឹងណាគេ?

ធី៖ ចារហ្នឹងមានតែឌុចហ្នឹង, ចារម៉ោហ៊ូអ្នកទទួលម៉ោ ។

សុជា៖ អញ្ចឹងអ្នកដាក់ចំនារហ្នឹងគឺឌុចហ្នឹងហើយអ្នកដាក់ម៉ោ ចុះបញ្ជីហ្នឹងយកម៉ោកន្លែងពូ អាបញ្ជីដែលគេដាក់ថាកម្ទេចអីហ្នឹងឲ្យម៉ោកន្លែងពូ?

ធី៖ យកម៉ោដើម្បីលុបក្នុងបញ្ជី ហើយនិងយកចេញតាមបន្ទប់ ព្រោះវានៅបន្ទប់ផ្សេងៗគ្នាទាំងអស់ឲ្យដឹង ។

សុជា៖ ចុះមានអ្នកទោសណាមួយដែលត្រូវដោះលែងទៅវិញទេ? តាមពូអ្នកកាន់បញ្ជី?

ធី៖ ដូចអត់មានទេ ។

សុជា៖ អត់ហ្នង?

ធី៖ អត់ហ្នងហ្នឹង ។

សុជា៖ ហើយអ្នកដែលចូលម៉ោហ្នឹង យូរបំផុត សួរចម្លើយប៉ុន្មានដងបានគេយកទៅកម្ទេច?

**ធី:** អានេះវាមិនទៀងវាស៊ីសង់លើគោលការណ៍របស់គេណោះ ដូនកាលក៏វាយូរ អាខ្លះក៏វាឆាប់ទៅ អាណឹងវាមិនទៀង ។

**សុជា:** ពូថាអត់មានអ្នកទោសដោះលែង ប៉ុន្តែអាចមានគេបញ្ជូនយកទៅកន្លែងផ្សេងៗដែរតើពូ ឬក៏អត់មានចេញពីកន្លែង?

**ធី:** ដូចអត់ឃើញដាក់ថាដោះលែងអីណា ។

**សុជា:** ចុះកាលជិនាន់ហ្នឹងដូចថាអ្នកទោសដែលគេចាប់ម៉ោកន្លែងទួលស្លែងហើយគេត្រូវបញ្ជូនទៅខាងព្រៃសវិញ ពូមានដែលមានទេ?

**ធី:** អត់មានទេ បើគេបម្រុងបញ្ជូនទៅព្រៃសគេបញ្ជូនទៅព្រៃសហើយ គេអត់មានបញ្ជូនម៉ោហ្នឹងទេ ព្រោះតែម៉ោហ្នឹងគេសុទ្ធតែចាប់ចង់មុខហើយ អាណឹងវាក្នុងលក្ខណៈផ្សេងហើយ បើគេបញ្ជូនទៅព្រៃសដូនកាលគេទៅដាក់ឲ្យព្រៃសនោះវិញហើយ គេមានអង្គភាពគេបញ្ជូនទៅណោះហ្នង ។

**សុជា:** ខ្ញុំធ្លាប់ជួបណាំ គេជាប់នៅព្រៃស គេនិយាយថា មុននឹងម៉ោកន្លែងព្រៃសហ្នឹងគេត្រូវបានគេចងមុខ ហើយគេនាំម៉ោទួលស្លែង បន្ទាប់ពីសួរចម្លើយបានរយៈពេលបីថ្ងៃបានគេបញ្ជូន គេបិទមុខចងបានគេបញ្ជូនទៅព្រៃសវិញ តើក្នុងករណីហ្នឹងពូមានដែលជួបប្រទះធ្លាប់ដែលដឹងដែរអត់?

**ធី:** អត់ដែលដឹង ប៉ុន្តែវាអញ្ចេះ ច្រើនតែកាលមុនអត់មានកាប់សម្លាប់កាលនៅនេះ នៅយើងនេះដាំដេង ជាប់គុកហ្នឹងមែន តែយកទៅឲ្យព្រៃស អស់ហ្នឹងយកទៅព្រៃសហើយ នេះទើបតែក្រោយម៉ោមិនដឹងយ៉ាងម៉េចចេញពីហ្នឹងសម្លាប់ ។

**សុជា:** តែចេញពីហ្នឹងយកទៅសម្លាប់ហ្នង?

**ធី:** បាទ! កាលមុនមានដោះលែងទៅព្រៃស កាលមុនអត់មានការសម្លាប់ទេ គ្រាន់តែម៉ោអប់រំ តែជិនាន់មុនវានៅសេនាធិការ ។

**សុជា:** ចុះអាគុកហ្នឹង អាគុកម៉ោដល់ស-២១, អាណឹងគុករបស់អីគេ?

**ធី:** អាណឹងស-២១ មិនដឹងជារបស់ អាណឹងមិនដឹងជារបស់សេនាធិការដែរខ្ញុំមិនបានដឹងច្បាស់ តែខ្ញុំដឹងថាដូចថាអង្គភាពស-២១ខ្ញុំសរសេរថា របស់សេនាធិការរហូត ហើយអ្នកទោសចាប់ក៏ដាក់ក្នុងក្រឡោនរបស់សេនាធិការដែរ ។

**សុជា:** កាលនៅស-២១?

**ធី:** ឈ្មោះបញ្ជីឈ្មោះអ្នកចាប់ ហើយបើចង់រកស-២១រកអត់ឃើញទេ អ្នកទោសស-២១រកអត់ឃើញទេ តែបើកក្នុងបញ្ជីសេនាធិការបានរកឃើញ ។

**សុជា:** ចុះពីណាអ្នកសរសេរកាន់បញ្ជីស-២១ ដាក់អក្សរស-២១?

**ធី:** ស-២១ប៉ុន្តែនៅក្នុងរបស់សេនាធិការក្រឡោនធំសេនាធិការ ប៉ុន្តែយើងសរសេរយុទ្ធជន ស-២១, ស-៧១ សុទ្ធនៅក្នុងសេនាធិការទាំងអស់ ។

**សុជា:** តែពូខ្ញុំដឹងម្យ៉ាងទៀត ប៉ុន្តែអ្នកដែលគេចាប់ អាណឹងប្រហែលជាក្រោយម៉ោហើយពេលដែលចាប់ផ្តើមមានយកមនុស្សទៅធ្វើការនៅព្រលានយន្តហោះកំពង់ឆ្នាំងណា៎ មានគេម៉ាចំនួនដែលខ្ញុំធ្លាប់សម្ភាសជួបទៅគេថា គេចាប់ពីកងពលផ្សេងៗម៉ោ យកម៉ោដាក់នៅទួលស្លែងតែមែនដាក់នៅក្នុងគុកធំហ្នឹងទេ គេដាក់នៅតាមផ្ទះល្វែងក្រៅអញ្ចេះ តែពួកគាត់ថាគាត់មិនបានចូលទៅក្នុងគុកទួលស្លែងហ្នឹងទេ ដូចថាគេយកម៉ោអញ្ចឹងគេគ្រាន់តែឃុំនៅតាមផ្ទះល្វែងផ្សេងៗទៀត នៅជុំវិញទួលស្លែងហ្នឹងណា៎ ហើយក្រោយម៉ោគេដោះលែងឲ្យទៅធ្វើការនៅកំពង់ឆ្នាំងអីវិញទៅ, ពូមានដែលឃើញទេ?

**ធី:** អាណឹងមែនការងារខ្ញុំ ខ្ញុំអត់ដឹង អានេះស៊ីសងលើឌុច នៅលើហ្នូហ្នឹងហើយ អានេះការងារគេដឹងនោះ ជួនកាលការងារដែលគេបញ្ជូនម៉ោគេត្រូវដោះលែងគេយកទៅអញ្ចឹងហើយ តែម៉ោក្នុងគុក បើតាមខ្ញុំដឹងគឺកម្រណាស់ ។

**សុជា:** ព្រោះមានអ្នកម៉ាចំនួនដែលខ្ញុំទៅសួរគេអះអាងថា គេចូលគុកទួលស្លែងហ្នឹងដែរ ហើយជួនកាលអ្នកខ្លះដូចថា នៅព្រៃស មានរូបថតនៅទួលស្លែងហ្នឹង អាណឹងមូលហេតុអីពូ? ដូចថាគេថតរូបអីមានគេបិតនៅទួលស្លែងហ្នឹងណា៎ ប៉ុន្តែការពិតគាត់ជាប់គុកនៅព្រៃស ពូមានដឹងមូលហេតុអីដែរទេ?

**ធី:** អត់ ។

**សុជា:** ពូធ្វើការនៅទួលស្លែងហ្នឹងមានដែលរៀននយោបាយរៀនអីទេ?

**ធី:** រៀននយោបាយ រៀនដែរម៉ាឆ្នាំរៀនម្តង ។

**សុជា:** ពីណាគេម៉ោបង្រៀន?

**ធី:** ឌុច ។

**សុជា:** ចុះមានសុន សេន, នួន ជា អីម៉ោទេ?

**ធី:** កាលហ្នឹងពូសួរថាសុន សេនម៉ោម្តង ។

**សុជា:** ពូបានរៀនជាមួយទេ?

**ធី:** កាលហ្នឹងគេហៅទៅរៀនទាំងអស់ ដូចបានរៀនមួយថ្ងៃហ្នឹងកាលហ្នឹង រៀនកន្លែង ។

**សុជា:** រៀននៅម្តុំណា?

**ធី:** កន្លែងសាលារៀន គេបង្កើតសាលារៀនហ្នឹង ។

**សុជា:** នៅជិតទួលស្លែងហ្នឹងហេ៎?

**ធី:** បាទ!

**សុជា:** ថ្នាក់ត្រឹមណាបានអាចទៅចូលរៀនទួលស្លែងបាន?

**ធី:** រៀនទាំងអស់គ្នាហ្នុង ទាំងយុទ្ធជនទាំងអី គ្រាន់តែដូរវេណគ្នាណា៎ អ្នកយាមព្រឹកអញ្ចឹងទៅរៀនទៅ តែរៀនដូចថាម៉ោថ្ងៃ.....

## Cassette N. 2

**សុជា:** រឿងខុចរៀនដូចថាខាងទង់បដិវត្តទង់អីណា អាណឹងថ្នាក់ត្រឹមណាបានអាចមើលបាន? ពូដែលឃើញទេអាសៀវភៅហ្នឹង? ពូដែលដឹងទេ?

**ធី:** អត់ដែលដឹងទេព្រោះការងារកាលហ្នឹងរឿងរៀនសូត្រអីអត់សូវប៉ុន្មានទេកាលហ្នឹង ។

**សុជា:** ចុះពូធ្លាប់អានទស្សនាវដ្ដីអីដែរកាលជំនាន់ហ្នុង?

**ធី:** មិនសូវជាបានមើលដែរ ។

**សុជា:** មិនសូវបានមើល ប៉ុន្តែពូធ្លាប់មើលដែរ? អញ្ចឹងមានន័យថាធ្លាប់មើលដែរ?

**ធី:** វាអត់ចាប់អារម្មណ៍នឹងមើលផងហ្នឹង ។

**សុជា:** អត់ចាប់អារម្មណ៍ទេ?

**ធី:** បាទ!

**សុជា:** ពូដូចថាអាកន្លែងពូធ្វើការ អាកន្លែងពូចុះបញ្ជីអីហ្នឹងពូនៅអគ្គុយនៅចាំចុះបញ្ជីហ្នឹងរហូតដូចថា ពីព្រឹកដល់ថ្ងៃ ពីល្ងាចដល់យប់ ពីយប់អីដល់ម៉ោងប៉ុន្មានអី ពូអគ្គុយនៅហ្នឹងរហូតអីក៏យ៉ាងម៉េច?

**ធី:** ខ្ញុំដេកនៅហ្នឹងហ្នុង គេឲ្យដាក់គ្រែដេកនៅកន្លែងប្រចាំការ ។

**សុជា:** ដេកនៅកន្លែងមាត់ទ្វារហ្នឹងហ្នុង?

**ធី:** កន្លែងគេនៅមុខបន្ទប់មួយ ។

**សុជា:** ដូចថាពេលដែលធ្វើការប្រចាំការហ្នឹងរហូតហ្នឹងហ្នុង អត់មានពេលសម្រាក ពេលឈប់ទៅធ្វើនៅកន្លែងនេះប៉ុន្មានម៉ោង ធ្វើនៅនោះប៉ុន្មានម៉ោង, អត់ទេ?

**ធី:** អត់ទេ ព្រោះតែអ្នកទោសម៉ោវាអត់ទៀង អ្នកបញ្ជូនម៉ោវាអត់ទៀង ជួនកាលយប់ ជួនណាម៉ោងមួយយប់ ជួនណាជិតភ្លឺ បើគេមិនឲ្យនៅអញ្ចឹងបានណាគេសរសេរទៅ មានតែខ្ញុំអ្នកសរសេរហ្នឹង ។

**សុជា:** មើលទៅពូដូចខុសពីកងការពារអី គេមានម៉ោងសម្រាក?

**ធី:** គេនេះ គេដូរវេណ ។

**សុជា:** ចុះពូមានតែម្នាក់ឯង?

ធីៈ មានតែម្នាក់ឯង ។

សុជាៈ ចុះក្មេងឈ្មោះឡាំនោះចេះសរសេរដែរ?

ធីៈ សរសេរវាអត់សូវត្រង់ជ្រុង វាគ្រាន់តែទំនប់បម្រើការងារជួយគ្នា ពេលទៅយកឈ្មោះយកអី វាទៅដើរតាមបន្ទប់តាមអីហ្នឹងណា៎ ។

សុជាៈ ហើយពូអត្តយចាំសរសេរទៅយើងចេះសរសេរ?

ធីៈ ហ្នឹងហើយ ។

សុជាៈ តែដល់ពេល ពូនិយាយមិញអ្នកទោសយកម៉ោពីឃុំពីអីចឹង ត្រូវទៅទទួល ត្រូវចុះឈ្មោះ?

ធីៈ អត់ទេគេយកម៉ោដល់កន្លែងខ្ញុំដេកហ្នឹងហ្មង កន្លែងហ្នឹងមានកន្លែងសរសេរ ។

សុជាៈ អាកន្លែងពូសរសេរហ្នឹងមានកន្លែងសំរាន្តរបស់ពូហ្មង?

ធីៈ ហ្នឹងហើយសំរាន្តហ្មង ។

សុជាៈ តែម៉ោគេដាស់ហើយណា៎?

ធីៈ តែម៉ោគេដាស់ហើយ ហើយបើយើងនេះ គ្រាន់តែបាយហើយគេបញ្ចូលម៉ោភ្លាមៗ ។

សុជាៈ អត់មានថាយកអ្នកទោសម៉ោអីយប់អី ចាំព្រលឹមឡើងចាំសរសេរអី គេអត់?

ធីៈ អត់ទេ, តែម៉ោថ្មើរម៉ានសរសេរថ្មើរហ្នឹង ។

សុជាៈ ពូដែលម៉ោលេងផ្ទះដែរ?

ធីៈ គ្រាន់តែចេញក្រៅរបងគេមិនឲ្យចេញផង រកទៅលេងផ្ទះ ។

សុជាៈ សុំគេម៉ោដែរ?

ធីៈ អត់ទេ មិនដែលសុំ ។

សុជាៈ ពូខ្ញុំឃើញប្រវត្តិរូបខ្លះគេវាយអត្តលីលេខណា៎ ចុះពូវាយដែរអីក៏អី?

ធីៈ បញ្ជីខ្លះវាយអត្តលីលេខហ្នឹង កាលហ្នឹងខ្ញុំខ្ជិលសរសេរវាយលេងទៅ ខ្លះវាយអាខ្លះ ។

សុជាៈ ពូចេះវាយដែរ?

ធីៈ វាយមួយៗ ។

សុជាៈ ពូនិយាយរួមទៅក្នុងអ្នកទោសម្នាក់តាំងពីពេលចូលម៉ោរហូតដល់ពេលចេញទៅគេយកទៅសម្លាប់ហ្នឹង ពូធ្វើបញ្ជីប៉ុន្មានដង? ហើយធ្វើនៅពេលណាខ្លះទៅពូ?

ធីៈ ចូលម៉ោធ្វើមួយសារ ចេញទៅវិញ បញ្ជីតែចូលម៉ោយើងធ្វើហើយ សរុបប្រចាំថ្ងៃឲ្យគេ ក្នុងមួយថ្ងៃចូលប៉ុន្មាននាក់ ព្រឹកព្រលឹមឡើងយើងយកទៅឲ្យមន្ទីរខាងសួរចម្លើយ ព្រោះមន្ទីរខាងសួរចម្លើយមន្ទីរនោះធំណាស់ មន្ទីរនោះមានបុគ្គលិកគេអ្នកវាយអត្តលីលេខគេច្រើនណាស់ ប៉ុន្តែដល់នេះក្រោយម៉ោចាប់ប្រធានស្ថាននៅហ្នឹងមួយទៅ ។

**សុជា:** ឈ្មោះអីគេ?

**ធី:** ម៉េង អ្នកសរសេរដូចខ្ញុំអញ្ចឹងដែរចាប់ទៅ កាលមុនខ្ញុំរាយការណ៍ទៅតាមរយៈហ៊ូស៊ីញ៉ៅឲ្យមន្ទីរហ្នឹង អត់បានជួបឌុចទេ ដល់ក្រោយម៉ោគេចាប់មន្ទីរហ្នឹងគេឲ្យទៅហ៊ូទៅ ។

**សុជា:** ចុះក្រោយពេលគេចាប់ម៉េងហ្នឹងមានណាគេទៅជំនួសម៉េង?

**ធី:** អត់មាន, ដូចអត់មាន មន្ទីរហ្នឹងវាមានអ្នកវៃអង្គុលីលេខ អត់មានណាទៅជំនួសផង ដូចថាឌុចគេក្តាប់ផ្ទាល់ហ្នឹង ។

**សុជា:** ពូស្គាល់គេអ្នកវៃអង្គុលីលេខហ្នឹងទេ?

**ធី:** អង្គុលីលេខហ្នឹងក្រោយម៉ោដូចទៅខ្លះចាប់ខ្លះនៅខ្លះអី មានច្រើនណាស់ ព្រោះថាអ្នកថតក៏នៅក្នុងមន្ទីរសួរចម្លើយហ្នឹងដែរ ។

**សុជា:** អ្នកថតរូប?

**ធី:** ជាងថតជាងអី ។

**សុជា:** បើយកអ្នកទោសម៉ោដំបូង, យកម៉ោសួរចម្លើយសិន ឬក៏យកម៉ោចូលគុកសិន?

**ធី:** យកម៉ោចូលគុកទាំងអស់អត់ទាន់សួរទេ ។

**សុជា:** ទាល់តែបានបញ្ជីពីកន្លែងពូទៅ?

**ធី:** អត់ទេ បញ្ជីគេណោះមានហើយ គេចុចឈ្មោះម៉ោគ្រាន់តែគេអ្នកសួរគេយកឈ្មោះពីណោះម៉ោទេ ម៉ោគ្រាន់តែយកឈ្មោះម៉ោយើងពិនិត្យត្រូវទុកបន្ទប់ណាៗឲ្យគេដឹង ។

**សុជា:** បានន័យថា ពេលដែលពូចុះបញ្ជីឈ្មោះរួច អ្នកទោសហ្នឹងនៅកន្លែងណា ឈ្មោះអី ធ្វើការងារអីបច្ចុប្បន្នជាប់នៅកន្លែងណាៗអញ្ចឹង ពូយកឈ្មោះហ្នឹងឆ្លងទៅហ៊ូ ឲ្យហ៊ូស៊ីញ៉ៅរួចបានពូយកបញ្ជីហ្នឹងទៅកន្លែងសួរចម្លើយ?

**ធី:** បាទ! យកទៅកន្លែងសួរចម្លើយ កន្លែងមន្ទីរគេណោះមួយទៀត ។

**សុជា:** ចាន់ចុងក្រោយម៉ោមានគេចាប់ទេ?

**ធី:** អត់ដឹងទេ ។

**សុជា:** តែនៅរហូតដល់៧៩ហ៎?

**ធី:** បាទ!

**សុជា:** ដូចថាពេលអ្នកទោសចូលម៉ោអញ្ចឹងពូត្រូវធ្វើបញ្ជីហើយពូត្រូវរៀបគេដាក់ទៅបន្ទប់ណាៗអីចឹងតើការបញ្ជូនទៅបន្ទប់ហ្នឹងមានបែងចែកជាប្រភេទ ឧបមាថាអ្នកទោសប្រភេទនេះត្រូវចូលបន្ទប់ផ្សេងៗគ្នា ឬក៏បន្ទប់លក្ខណៈតែមួយពូ?

ធីៈ បន្ទប់វាមានបន្ទប់តូចៗអញ្ចឹង បើបន្ទប់ណាទំនេរៗចេះតែរុញចូលទៅ ហើយយើងនេះទៅស្រន់ទៅតាមបន្ទប់ហ្នឹងម៉ោ ស៊ីសងខាងគេចាត់ចែងតើ ។

សុជាៈ ចុះអាបន្ទប់ពិសេសៗសម្រាប់ផ្ទាក់កងពល វរៈអី?

ធីៈ អាណឹងគេយកទៅកន្លែងផ្សេងណ៎ ។

សុជាៈ ពូអ្នកកាន់បញ្ជីហ្នឹងដែរ?

ធីៈ អាណឹងយើងអ្នកកាន់បញ្ជីដែរ ប៉ុន្តែកាលនេះគេឲ្យឈ្មោះម៉ោអញ្ចេះហើយយើងអត់មានបានទៅសួរទេ ។

សុជាៈ គេឲ្យឈ្មោះម៉ោយើងទៅចម្លងតាមគេម៉ោ?

ធីៈ ចម្លងតាមគេម៉ោ ។

សុជាៈ ប៉ុន្តែបើឈ្មោះយុទ្ធជនធម្មតាយើងសួរគេសរសេរដាក់?

ធីៈ ហ្នឹងហើយសួរឈ្មោះសួរអី ។

សុជាៈ ពូនិយាយថាការរៀបចំបន្ទប់ គេរៀបម៉ោឲ្យពូស្រេចឬមួយក៏ពូចាត់ចែង?

ធីៈ អត់ទេ កងការពារតែគេម៉ោដល់ តែខ្ញុំសរសេរស្រេចហើយគេបញ្ចូលក្នុងបន្ទប់ហើយ ហើយបានខ្ញុំដើរស្រន់តាមបន្ទប់វិញ ព្រោះខ្ញុំគ្មានកម្លាំងណាទៅយកអ្នកទោសទៅដាក់បន្ទប់អីអត់មានទេ គ្រាន់តែធ្វើនេះហើយអញ្ចឹងទៅ ខ្ញុំសរសេរហើយអញ្ចឹងទៅ កងការពារយកទៅ នាំម៉ោក៏កងការពារនាំម៉ោទាំងអស់ នាំពីក្រៅម៉ោ ហើយបានខ្ញុំសរសេរហើយបានគេបញ្ចូលក្នុងបន្ទប់ហើយបានខ្ញុំដើរសួរម៉ោថ្មីបន្ទប់ណាៗខ្វះគេប្រាប់ ។

សុជាៈ ពូទៅសួរខាងណាវិញ?

ធីៈ សួរអ្នកយាមហ្នឹងដឹងហើយ ព្រោះអ្នកយាមប្រចាំការនៅហ្នឹងគេដឹងហើយ ។

សុជាៈ ពូម្នាក់ទៀតដែលឈ្មោះឡាំហ្នឹង ឧបមាថា កាលគេម៉ោនៅជាមួយពូ ពូបង្រៀនហ្នឹង កាលហ្នឹងពូដូចថា ពូចង់បង្រៀនឲ្យម្នាក់ហ្នឹងចេះដែរ ឬក៏ពូមានគំនិតមួយថា អត់ចង់បង្រៀនឲ្យម្នាក់ហ្នឹងចេះ ខ្លាចក្រែងគេចេះទៅគេយ៉ាងម៉េចទៀត?

ធីៈ អត់មានរឿងបង្រៀនទេ គេម៉ោហ្នឹង គេជួយយើងគេធ្វើអីធ្វើទៅ យើងមានឈ្មោះយើងប្រាប់ឲ្យគេធ្វើទៅ សរសេរប្រវត្តិរូបសរសេរអីតាមហ្នឹងទៅ ។

សុជាៈ ចុះកាលហ្នឹងពូគិតម៉េចនៅពេលដែលគេឲ្យមនុស្សម្នាក់ហ្នឹងម៉ោជួយពូ?

ធីៈ ខ្ញុំនៅហ្នឹងនិយាយត្រង់មួយថ្ងៃៗខ្ញុំចេះតែបារម្ភ ព្រោះវរសេនាតូចខ្ញុំមើលក្នុងកងពល១២ឃើញអ្នកស្គាល់ៗគ្នាកាលសង្គ្រាមណ៎ ហើយខ្ញុំអារម្មណ៍ចេះតែនឹកឃើញភ័យៗ ។

សុជាៈ ដូចថាវរសេនាតូចដែលពូនៅជាមួយគ្នាហ្នឹងគេត្រូវម៉េច គេចាប់?

ធី: គេចាប់ ។

សុជា: ពូដឹងពីមូលហេតុដែលគេចាប់ហ្នឹងដែរអត់?

ធី: អត់ដឹង ព្រោះយើងអត់មានសិទ្ធិសួរ ។

សុជា: តែពូស្មានដឹងថាគេចាប់ហ្នឹងមូលហេតុអី?

ធី: ព្រោះតែចាប់ហ្នឹង ចាប់ហ្នឹងវរសេនាធំ ជាប់ដោយម៉ោវរសេនាតូចទៅ ដោយម៉ោអនុសេនាធំទៀតទៅ រឿងរ៉ាវពិតយើងមិនអាចដឹង ហើយបើយើងហ៊ានដេជីកសួរអ្នកទោសអីណាស្រេចចិត្តទៀតនោះរឿងរ៉ាវធំហើយ ។

សុជា: ចុះអ្នកទោសបរទេសផ្សេងៗទៀត ខាងស្បែកសអីនោះ ពេលចូលម៉ោឆ្លងកាត់ខាងពូដែរអីក៏យ៉ាងម៉េច?

ធី: អត់ទេ ម្នាក់ពីរនាក់អញ្ចឹងគេមិនសូវឲ្យយើងដឹងទេ គេគ្រាន់តែឲ្យឈ្មោះទេ គេទៅគេយកទៅកន្លែងគុកគេហ្នឹងហើយ ។

សុជា: ប៉ុនពូដែលឃើញអ្នកទោសអីពួកស្បែកសអីចូលម៉ោទេ?

ធី: ចុះអាណឹងតែមានឈ្មោះម៉ោដឹងថាមានពួកស្បែកសរចូលម៉ោហើយ ។

សុជា: មានតែឈ្មោះ ប៉ុន្តែពូដែលបានឃើញផ្ទាល់ភ្នែកថាអ្នកទោសហ្នឹងបានចូលម៉ោអីចឹង?

ធី: វាអត់ចូលម៉ោកន្លែងខ្ញុំទេ ចូលម៉ោចូលទៅកន្លែងគុកហ្នឹងហ្នុង មនុស្សសំខាន់គេយកចូលកន្លែងគុក អត់ដែលយកចូលម៉ោកន្លែងខ្ញុំសរសេរទេ ។

សុជា: ប៉ុនកន្លែងពូនៅកន្លែងមាត់ទ្វារគុកហ្នឹងអីក៏យ៉ាងម៉េច?

ធី: មាត់ទ្វារគុក ប៉ុន្តែកន្លែងហ្នឹងវាបាំងអញ្ចេះ អាបន្ទប់ហ្នឹងវាមិនបាំង បាំងហ្នឹងអាកន្លែងបន្ទប់ក្នុងនេះហ្នឹង យើងមានបានទៅមើលនេះណា ហើយវាមិនសូវបានដាគិតគូរចេញចូលអីណា ណាគេយកម៉ោណា ខ្ញុំគិតតែពីការងារយើងនិយាយឲ្យខ្លីទៅ ។

សុជា: ពូក្នុងមួយថ្ងៃអ្នកទោសចូលក្នុងជាមធ្យមប្រហែលជាប៉ុន្មាននាក់ដែរ?

ធី: អត់ដឹងពិតប្រាកដទេ, អត់ចាំទេ ទាល់តែយើងមើលក្នុងបញ្ជីរហ្នុង ព្រោះបញ្ជីនៅទាំងអស់មើលដឹងស្ថិតិហើយ ។

សុជា: ហើយឧបមាថាអ្នកទោសដែលចូលម៉ោហ្នឹងភាគច្រើនគេចាប់ម៉ោម្នាក់ៗឯង ឬក៏ម៉ោទាំងគ្រួសារអី?

ធី: ប៉ុន្តែវាមិនបានដឹង ព្រោះគេបញ្ជូនម៉ោហ្នឹង អ្នកទោសមានគ្រប់ផ្នែកទាំងអស់ វាមានអាអ្នកខ្លះម៉ោពីកងពលនេះ អ្នកខ្លះម៉ោពីតំបន់នេះអាខ្លះតំបន់នោះ គេមានចូលកន្លែងគេណាមួយហើយបានយើងទៅយក ។

សុជា៖ ពូដូចខ្ញុំឃើញក្នុងរូបថត មានអ្នកទោសខ្លះមានកូនមានអី ពេលដែលចាប់យកម៉ោហ្នឹងមានកូន យកម៉ោពីនេះហ្នង ឬក៏កូនហ្នឹងឆ្លងទន្លេអីក្នុងគុកហ្នឹង? ខ្ញុំឃើញរូបថតខ្លះមានកូន ។

ធី៖ កូនពីណោះម៉ោ ។

សុជា៖ ចុះដល់ពេលគេយកម្ដាយទៅ, ដល់ពេលយើងចុះបញ្ជីចុះទាំងកូនហ្នឹងដែរ ឬក៏ចុះតែម្ដាយ?

ធី៖ ចុះតែម្ដាយ ។

សុជា៖ ចុះពេលដែលយកម្ដាយទៅដាក់គុក?

ធី៖ កូនហ្នឹងនៅជាមួយម្ដាយ ។

សុជា៖ ចុះពេលយកម្ដាយហ្នឹងទៅកម្ទេច?

ធី៖ កូនហ្នឹងយកទៅជាមួយគ្នាហ្នឹង ។

សុជា៖ ហើយរឿងចុះបញ្ជីអត់មានចុះទេកូន?

ធី៖ អត់ទេកូន ។

សុជា៖ គេអត់មានថា បើយកម្ដាយទៅហើយកូនហ្នឹងយកម៉ោដាក់កន្លែងកុមារកន្លែងអីគេ គេអត់មានទេហេ៎! នៅគុកទួលស្លែងហ្នឹង?

ធី៖ អត់ ។

សុជា៖ មានច្រើនករណីទេអ្នកដែលគេចាប់ម៉ោមានកូនដែត កូនអីម៉ោតាមហ្នឹង?

ធី៖ មានដែរ តែវាតិចតួចទេ ។

សុជា៖ អរគុណពូច្រើនដែលរំខានពូលើកទីពីរ

**ចប់**